ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១~ព្រះរាជក្រម

១៣-៣-២០១៣-ព្រះរាជក្រម នស/រកម/០៣១៣/០០៣ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនហាយដ្រូ ផៅវើរ ឡូវើរ សេសាន្ត ២ ២៧៦៣

២~ព្រះរាជក្រឹត្យ

១៣-៣-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០៣១៣/២២៨ ស្តីពី ការដំឡើងឋានន្តរស័ក្តិជូនឯកឧត្តម **គឹម ហុង** ពីឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៣ ទៅឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ២៧៧៦

១៩-៣-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៣១៣/២២៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ព្រះតេជគុណ ឯកឧត្តម អស់លោក លោកស្រី ជាមន្ត្រីរាជការ និងសប្បុរសជន ចំនួន ៧០ រូប ២៧៧៧

១៩-៣-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៣១៣/២៣០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ព្រះតេជគុណ ឯកឧត្តម លោកជំទាវ ឧកញ៉ា អស់លោក លោកស្រី ជាមន្ត្រីរាជការ និងសប្បុរសជន ចំនួន ៦៦ រូប ២៧៧៩

១៩-៣-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៣១៣/២៣១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ០៧ រូប ២៧៨១

១៩-៣-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៣១៣/២៣៤ ស្តីពី ការប្តូរប្រភេទក្របខ័ណ្ឌ ស្របតាមឧបនិស្ស័យមុខតំណែង ជូនមន្ត្រីរាជការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន ០១ រូប ពីមន្ត្រីក្នុងឋានន្តរស័ក្តិនាយក្រមការ នៃ ក្របខ័ណ្ឌក្រមការ ទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលមន្ត្រីរាជការក្នុងឋានន្តរស័ក្តិ អនុមន្ត្រី ជាករណីពិសេស ២៧៨២

១៩-៣-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៣១៣/២៣៥ ស្តីពី ការតែងតាំងអស់លោក ចំនួន ០៣ រូប ជា ឧកញ៉ា ២៧៨៣

១៩-៣-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៣១៣/២៣៨ ស្តីពី ការកាត់ផ្ទៃដីទំហំ ៦៤៧,៤០ ហិកតា ពីរមណីយដ្ឋានប្រាសាទព្រះវិហារ ដែលកំណត់ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៥២ ចុះ ថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០១១ ២៧៨៤

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

១៨-៣-២០១៣-អនុក្រឹត្យលេខ ១០៩ អនក្រ.បក ស្តីពី បែបបទ និងនីតិវិធីនៃការដាក់ឈ្មោះផ្លូវ ឬ លេខផ្លូវ និងការកែប្រែឈ្មោះផ្លូវ ឬ លេខផ្លូវ ២៧៨៥

-អនុក្រឹត្យលេខ ***១១០, ១១១, ១១២, ១១៣, ១១៤, ១១៥, ១១៦*** *អនក្រ.បក មិនទាន់បានទទួល*

២០-៣-២០១៣-អនុក្រឹត្យលេខ ១១៧ អនក្រ.បក ស្តីពី ការដំឡើងស្ថានីយ៍ផលិតគ្រាប់ពូជទី ១ ទៅជាវិទ្យាស្ថានជាតិស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មសម្តេចតេជោ ហ៊ុន សែន ២៨០១

-អនុក្រឹត្យលេខ ***១១៨, ១១៩, ១២០, ១២១, ១២២, ១២៣, ១២៤, ១២៥, ១២៦, ១២៧,*** *អនក្រ.បក មិនទាន់បានទទួល*

២១-៣-២០១៣-អនុក្រឹត្យលេខ ១២៨ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ២៨០៤

២១-៣-២០១៣-អនុក្រឹត្យលេខ ១២៩ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ២៨០៦

១៣-១២-២០១២-អនុក្រឹត្យលេខ ២៩១៦ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ២៨០៨

១៣-១២-២០១២-អនុក្រឹត្យលេខ ២៩១៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២៨១២

១៣-១២-២០១២-អនុក្រឹត្យលេខ ២៩១៨ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិ នាយទាហាន ២៨១៣

១៣-១២-២០១២-អនុក្រឹត្យលេខ ២៩១៩ អនក្រ.តត ស្តីពី ការតែងតាំងមុខងារ នាយទាហាន ២៨១៥

១៣-១២-២០១២-អនុក្រឹត្យលេខ ២៩២០ អនក្រ.តត ស្តីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ២៨១៦

១៣-១២-២០១២-អនុក្រឹត្យលេខ ២៩២១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២៨១៨

១៣-១២-២០១២-អនុក្រឹត្យលេខ ២៩២២ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ២៨១៩

១៣-១២-២០១២-អនុក្រឹត្យលេខ ២៩២៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៨២១

១៣-១២-២០១២-អនុក្រឹត្យលេខ ២៩២៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២៨២៣

១៣-១២-២០១២-អនុក្រឹត្យលេខ ២៩២៥ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ២៨២៦

១៤-១២-២០១២-អនុក្រឹត្យលេខ ២៩២៦ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងនាយនគរបាលជាតិ ២៨២៨

១៤-១២-២០១២-អនុក្រឹត្យលេខ ២៩២៧ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៨២៩

១៧-១២-២០១២-អនុក្រឹត្យលេខ ២៩២៨ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិ នាយទាហាន ២៨៣០

១៧-១២-២០១២-អនុក្រឹត្យលេខ ២៩២៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២៨៣៣

១៧-១២-២០១២-អនុក្រឹត្យលេខ ២៩៣០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២៨៣៤
១៧-១២-២០១២-អនុក្រឹត្យលេខ ២៩៣១ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៨៣៥
១៧-១២-២០១២-អនុក្រឹត្យលេខ ២៩៣២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២៨៣៦
១៧-១២-២០១២-អនុក្រឹត្យលេខ ២៩៣៣ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៨៣៧
១៧-១២-២០១២-អនុក្រឹត្យលេខ ២៩៣៤ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៨៣៨
១៧-១២-២០១២-អនុក្រឹត្យលេខ ២៩៣៥ អនក្រ.តត ស្តីពី ការតែងតាំង និង ដំឡើងឋានន្តរស័ក្តិ
ជូនមន្ត្រីរាជការ ២៨៣៩
១៧-១២-២០១២-អនុក្រឹត្យលេខ ២៩៣៦ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ២៨៤០
១៧-១២-២០១២-អនុក្រឹត្យលេខ ២៩៣៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២៨៤២
១៧-១២-២០១២-អនុក្រឹត្យលេខ ២៩៣៨ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ២៨៤៤
១៧-១២-២០១២-អនុក្រឹត្យលេខ ២៩៣៩ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ២៨៤៥
១៨-១២-២០១២-អនុក្រឹត្យលេខ ២៩៤០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២៨៤៦
១៨-១២-២០១២-អនុក្រឹត្យលេខ ២៩៤១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២៨៤៧
១៨-១២-២០១២-អនុក្រឹត្យលេខ ២៩៤២ អនក្រ.តត ស្តីពី ការដំឡើងថ្នាក់ជូនមន្ត្រីរាជការ ២៨៤៨
១៨-១២-២០១២-អនុក្រឹត្យលេខ ២៩៤៣ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ២៨៥១
១៨-១២-២០១២-អនុក្រឹត្យលេខ ២៩៤៤ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងនាយនគរបាលជាតិ ២៨៥២
១៨-១២-២០១២-អនុក្រឹត្យលេខ ២៩៤៥ អនក្រ.តត ស្តីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល
នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ២៨៥៣
១៨-១២-២០១២-អនុក្រឹត្យលេខ ២៩៤៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២៨៥៥
១៨-១២-២០១២-អនុក្រឹត្យលេខ ២៩៤៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៨៥៦
១៨-១២-២០១២-អនុក្រឹត្យលេខ ២៩៤៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២៨៥៧
១៨-១២-២០១២-អនុក្រឹត្យលេខ ២៩៤៩ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៨៥៨
១៨-១២-២០១២-អនុក្រឹត្យលេខ ២៩៥០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៨៥៩
១៨-១២-២០១២-អនុក្រឹត្យលេខ ២៩៥១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២៨៦០

២_សេចក្តីសម្រេច

១៧-៣-២០១៣-សេចក្តីសម្រេចលេខ ១២ សសរ ស្តីពី និរាករណ៍សេចក្តីជូនដំណឹងរបស់ទីស្តីការ
គណៈរដ្ឋមន្ត្រី លេខ ៦៦៩ ស.ជ.ណ ចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០១១ ២៨៦១

ឃ

III-ការងារបណ្តាក្រសួង

ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
និង
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

២៨-១២-២០១២ - ប្រកាសរួមលេខ ១០០៩ សហវ.ប្រក ស្តីពី ការផ្តល់សេវាសាធារណៈរបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២៨៦២

២៨-១២-២០១២ - ប្រកាសរួមលេខ ១០១០ សហវ.ប្រក ស្តីពី ការផ្តល់រង្វាន់លើកទឹកចិត្តជូន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ២៨៧២

ព្រះរាជក្រម

នស/រកម/០៣១៣/០០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុនហាយដ្រូ ផៅវើរ ឡូវើរ សេសាន្ត២ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី២ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើការធានាទូទាត់របស់
រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឲ្យ
ក្រុមហ៊ុនហាយដ្រូ ផៅវ័រ ឡូវើរ សេសាន្ត២

មាត្រា ១.-

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំពោះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអគ្គិសនីកម្ពុជាឲ្យក្រុមហ៊ុនហាយដ្រូ ផៅវ័រ ឡូវើរ សេសាន្ត២ ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង ក្រុមហ៊ុនហាយដ្រូ ផៅវ័រ ឡូវើរ សេសាន្ត២ និងកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនី រវាងអគ្គិសនីកម្ពុជា និង ក្រុមហ៊ុនហាយដ្រូ ផៅវ័រ ឡូវើរ សេសាន្ត២ ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ នាថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ។ ការធានានេះមានអត្ថបទទាំងស្រុងដែលបានចុះហត្ថលេខាកាលពីថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃរាជរដ្ឋាភិបាលកម្ពុជា ភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តលិខិតធានាទូទាត់នេះ ។

មាត្រា ៣.-

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

នស.១៣០៣.២២៥

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ:៤២០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០១៣

អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សយ សុខា

2/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...០០៧....សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ ២០១២

លិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់

ជូនចំពោះ ៖ លោកប្រធាន ក្រុមហ៊ុន ហាយដ្រូ ផៅវ័រ ឡូវើរ សេសាន្ត២
(Hydro Power Lower Sesan 2 Co., Ltd.)

អាសយដ្ឋាន៖ លេខ ២៤៦, មហាវិថីព្រះមុនីវង្ស, សង្កាត់បឹងរាំង, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

ទូរសារ ៖ ៨៥៥ ២៣ ៤២៦ ៤១៥

យោង ៖

(ក) សិទ្ធិប្រទាន លេខ ១២០ សប្រទ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១២ ដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា (លិខិតសិទ្ធិប្រទានក្នុងឧបសម្ព័ន្ធ១) ។

(ខ) កិច្ចព្រមព្រៀងអនុវត្តគម្រោង (IA) ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ ដែលបានចុះហត្ថលេខារវាងរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយ រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (ឧ.រ.ថ) និងក្រុមហ៊ុន ហាយដ្រូ ផៅវ័រ ឡូវើរ សេសាន្ត២ (Hydro Power Lower Sesan 2 Co., Ltd.) (ក្រុមហ៊ុន) ។

(គ) អគ្គិសនីកម្ពុជា ជាសហគ្រាសរដ្ឋ មានការទទួលខុសត្រូវមានកំណត់ បានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៩៦ មានការិយាល័យធំរបស់ខ្លួន តាំងនៅផ្លូវលេខ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា រាប់បញ្ចូលទាំងអ្នកបន្តវេន និងអ្នកដែលបានអនុញ្ញាតឱ្យទទួលសិទ្ធិ (អ.ក), បានចុះកិច្ចព្រមព្រៀងទិញអគ្គិសនី (PPA) ជាមួយក្រុមហ៊ុន ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ ។

(ឃ) រាជរដ្ឋាភិបាលកម្ពុជា យល់ព្រមផ្តល់ ៖ (១)-ការធានាលើការទូទាត់ថ្លៃទិញថាមពលអគ្គិសនីក្នុងករណីដែល អ.ក មិនធ្វើការទូទាត់ និង (២)-ការធានាលើការទូទាត់បញ្ចប់កិច្ចព្រមព្រៀងស្របតាមកិច្ចព្រមព្រៀង PPA និង/ឬ IA និងក្នុងករណីដែលក្រុមហ៊ុន មិនអាចដំណើរការគម្រោងបាន ដែលបណ្តាលមកពីព្រឹត្តិការណ៍ប្រធានសក្តិនយោបាយ ។

(ង) តាមការតម្រូវក្នុងប្រការ ៥.៣ នៃកិច្ចព្រមព្រៀងអនុវត្តគម្រោង រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ស.ហ.វ) ជំនួសមុខឱ្យរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា (អ្នកធានា) បានយល់ព្រមចុះហត្ថលេខា លើលិខិតធានាលើការទូទាត់ ដែលជាកាតព្វកិច្ចរបស់ អ.ក ឬឧ.វ.ថ ស្របតាម PPA និង IA ។

ដូច្នេះ យើងខ្ញុំសូមធានា ថា ៖

១. អ្នកធានាសូមធានា និងសន្យា ដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធ ទូទាត់ឱ្យក្រុមហ៊ុន នូវចំនួនទឹកប្រាក់ណាមួយ និងទាំងអស់ ដែលត្រូវបង់ និងជំពាក់ដោយ ឧ.វ.ថ ឬ អ.ក ឱ្យក្រុមហ៊ុន ក្រោមកិច្ចព្រមព្រៀង IA ឬ PPA ដែល ឧ.វ.ថ ឬ អ.ក ខកខានពុំបានទូទាត់ អនុលោមតាមអាណត្តិ នៃ IA ឬ PPA (លិខិតធានា) ។

២. លិខិតធានានេះ ត្រូវជាការធានាបន្តរហូត និងឱ្យបានសមស្រប និងត្រូវទូទាត់តុល្យការទឹកប្រាក់ ដែលត្រូវបង់ឱ្យក្រុមហ៊ុនគ្រប់ពេល ដោយ ឧ.វ.ថ ឬ អ.ក ក្រោមកិច្ចព្រមព្រៀង IA ឬ PPA ទោះជាមានលិខិតជូនដំណឹងណាមួយ ស្តីពីការបញ្ចប់កិច្ចព្រមព្រៀង ឬការរំលាយ ឬអសមត្ថភាព ឬការផ្លាស់ប្តូរណាមួយ ក្នុងព្រះរាជក្រឹត្យពាក់ព័ន្ធនឹង ឧ.វ.ថ ឬ អ.ក ឬក្នុងនាម ឬរបៀប ឬការទូទាត់គណនីណាមួយ ឬបញ្ហាផ្សេងទៀតក៏ដោយ ។

៣. មុនពេលឈានដល់ការអនុវត្តលិខិតធានានេះ និងធ្វើសំណើសុំការទូទាត់ពីអ្នកធានា ក្រុមហ៊ុនត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរ ស្នើសុំការទូទាត់ពី ឧ.វ.ថ ឬ អ.ក ។ ក្រោយរយៈពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃវិក្កយបត្រ ដូចមានចែងក្នុងប្រការ ៨.៧.១ នៃ PPA ឬសំណើសុំទូទាត់ណាមួយពីក្រុមហ៊ុន ទៅ ឧ.វ.ថ ត្រូវបានទទួលដោយ អ.ក ឬ ឧ.វ.ថ ក្រុមហ៊ុនអាចជូនដំណឹងទៅអ្នកធានា ជាលាយលក្ខណ៍អក្សរថា ការទូទាត់ ដោយ ឧ.វ.ថ ឬ អ.ក បានហួសកាលកំណត់ និងលើកសំណើសុំទូទាត់ពីអ្នកធានា ស្របតាមលិខិតធានានេះ ហើយអ្នកធានា ត្រូវធ្វើការទូទាត់ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ។ ការយឺតយ៉ាវក្នុងការទូទាត់ របស់អ្នកធានា ក្រោមលិខិតធានានេះ ត្រូវគិតការប្រាក់តាមអត្រាការប្រាក់ប្រចាំឆ្នាំ LIBOR បូក ៣% (បីភាគរយ) ។ ពុំមានសំណើណាមួយ ដែលធ្វើឡើងដោយក្រុមហ៊ុន ស្របតាមលិខិតធានានេះ ដែលប៉ះពាល់ ឬជំទាស់សិទ្ធិ របស់ក្រុមហ៊ុន ក្នុងការធ្វើសំណើបន្ថែម ឬផ្សេងទៀត ចំពោះវិក្កយបត្រ ដែលមិនទាន់ទូទាត់ផ្សេងទៀត ។

ទឹកប្រាក់ទាំងអស់ ដែលអ្នកធានាត្រូវទូទាត់តាមលិខិតធានានេះ ត្រូវបង់ទាំងអស់ចូលក្នុងគណនីធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលក្រុមហ៊ុនបានកំណត់ ជាប្រាក់ដុល្លារអាមេរិកឱ្យក្រុមហ៊ុន ។

៤. រាល់សំណើសុំទូទាត់ ដែលបានធ្វើឡើងតាមលិខិតធានានេះ ត្រូវធ្វើឡើងតាមរយៈអ្នកនាំសំបុត្រ ឬដោយផ្ទាល់ ដោយមន្ត្រីទទួលបានការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន នៅការិយាល័យរបស់

អ្នកធានា និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ ដែលមានចុះហត្ថលេខាដោយមន្ត្រី ដែលបានទទួលការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន ដោយគ្មានកាតព្វកិច្ចណាផ្សេងទៀត បញ្ជាក់ថា ៖

"យើងខ្ញុំ សូមបញ្ជាក់ថា ៖

(១). ក្រុមហ៊ុន ហាយដ្រូ ផៅវ័រ ឡូវើរ សេសាន២ (ក្រុមហ៊ុន) បានធ្វើសំណើសុំទូទាត់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អ្នកធានា) នូវចំនួនទឹកប្រាក់...................... {បញ្ចូលទឹកប្រាក់} ដុល្លារអាមេរិក ស្របតាមចំណុចទី១ នៃលិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់ ចុះថ្ងៃទី.......ខែ.........ឆ្នាំ.......... រវាង អ្នកធានា និងក្រុមហ៊ុន ។

(២). ចំនួនទឹកប្រាក់ខាងលើ គឺដល់កាលកំណត់ និងត្រូវទូទាត់ដោយ អ.ក ឬ ឧ.រ.ថ ស្របតាម PPA/IA រវាងក្រុមហ៊ុន និង អ.ក ឬឧ.រ.ថ និងពុំមានផ្នែកណាមួយនៃចំនួនទឹកប្រាក់ដែលបានបញ្ជាក់ខាងលើ ជាកម្មវត្ថុនៃវិវាទ រវាង អ.ក ឬឧ.រ.ថ និងក្រុមហ៊ុន នោះទេ ។

(៣). សំណើសុំទូទាត់ពី ឧ.រ.ថ ឬអ.ក ជាលាយលក្ខណ៍អក្សរ បានធ្វើរួចហើយ ។

(៤). ចំនួនទឹកប្រាក់នេះ នៅពុំទាន់បានទូទាត់ដោយ ឧ.រ.ថ ឬអ.ក រហូតដល់ថ្ងៃនេះ ។

៥. អ្នកធានាសូមអះអាង និងធានា នៅថ្ងៃនេះថា ៖

- អ្នកធានាមានសិទ្ធិពេញសមត្ថភាព និងការអនុញ្ញាតស្របច្បាប់ ក្នុងការទទួលកាតព្វកិច្ច ការចុះហត្ថលេខា និងការប្រគល់ ព្រមទាំងប្រតិបត្តិ និងអង្កេតអាណត្តិ និងបញ្ញត្តិនានា នៃលិខិតធានានេះ ។
- លិខិតធានានេះ ជាកាតព្វកិច្ចរបស់អ្នកធានា ស្របច្បាប់ មានសុពលភាព ប្រសិទ្ធភាព និងជាចំណងផ្លូវច្បាប់ អនុលោមតាមអាណត្តិ របស់លិខិតធានានេះ ។
- រាល់សកម្មភាពចាំបាច់ត្រូវបានអនុវត្ត និងរាល់ការយល់ព្រមដែលតម្រូវឱ្យមាន ត្រូវបានទទួលរួចហើយ ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សិទ្ធិក្នុងការចុះហត្ថលេខា ការប្រគល់ និងការប្រតិបត្តិលិខិតធានានេះ ។
- កាតព្វកិច្ច និងការព្រមព្រៀងនានារបស់អ្នកធានា ក្នុងលិខិតធានានេះ ជាកាតព្វកិច្ចដោយគ្មានលក្ខខណ្ឌរបស់អ្នកធានា ដែលក្នុងការអនុវត្តកាតព្វកិច្ចទាំងនេះ ជំនឿទុកចិត្ត និងកិត្តិយសរបស់អ្នកធានា ត្រូវបានប្រកាន់ខ្ជាប់ ។
- អ្នកធានា បានយល់ព្រមដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធថា ការចុះហត្ថលេខា ការប្រគល់ និងការអនុវត្តដោយអ្នកធានា តាមលិខិតធានានេះ គឺជាសកម្មភាពពាណិជ្ជកម្ម មិនមែនជាសកម្មភាពសាធារណៈ ឬជាសកម្មភាពរដ្ឋាភិបាលទេ ហើយលិខិតធានានេះ ជាកាតព្វកិច្ចដោយផ្ទាល់ ដោយគ្មានលក្ខខណ្ឌ និងដោយមិនអាចបដិសេធបានឡើយ ។
- ប្រសិនបើមានបណ្តឹងណាមួយ ចំពោះអ្នកធានា ឬចំពោះទ្រព្យសម្បត្តិរបស់អ្នកធានា ក្នុងយុត្តាធិការណាមួយ ដែលទាក់ទងនឹងកិច្ចព្រមព្រៀងនេះ ពុំមានអភ័យឯកសិទ្ធិណាមួយពី

បណ្តឹងនោះ ត្រូវបានទាមទារដោយ ឬតាងនាមរបស់ខ្លួន ឬទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់ខ្លួន ដែលមានបច្ចុប្បន្ន ឬអាចទទួលបាននាពេលអនាគត ។

៦. លិខិតធានានេះ ត្រូវមានសុពលភាព និងប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទសាងសង់ (Construction Commencement Date) រហូតដល់ចប់អាណត្តិ នៃ IA ឬ PPA និងត្រូវបន្តពេលយូរតទៅទៀត តាមចំនួនទឹកប្រាក់ណាមួយ ដែល អ.ក នៅជំពាក់ក្រុមហ៊ុន ទាក់ទងនឹងអាណត្តិនេះ ឬនៅពុំទាន់ទូទាត់ ។

៧. គ្មានការខកខាន ឬការយឺតយ៉ាវណាមួយ ដោយក្រុមហ៊ុន ក្នុងការអនុវត្តសិទ្ធិ ឬការដោះស្រាយក្រោមលិខិតធានានេះ ត្រូវបានចាត់ទុកជាការបោះបង់សិទ្ធិ ឬការដោះស្រាយនោះឡើយ ។ គ្មានការអនុវត្តសិទ្ធិ ឬការដោះស្រាយតែមួយ ឬតែមួយផ្នែក រាំងការអនុវត្តបន្ថែមនូវសិទ្ធិ ឬការដោះស្រាយណាមួយផ្សេងទៀតឡើយ ។ ការបដិសេធរបស់ក្រុមហ៊ុន មានប្រសិទ្ធភាពលុះត្រាតែការបដិសេធនោះ ធ្វើឡើងជាលាយលក្ខណ៍អក្សរ ។ សិទ្ធិ និងការដោះស្រាយនានា ដែលបានផ្តល់ឱ្យក្រុមហ៊ុន ដោយលិខិតធានានេះ គឺជាការផ្តល់បន្ថែម និងមិនលើកលែងសិទ្ធិ និងការដោះស្រាយណាមួយ ដែលត្រូវបានផ្តល់ដោយច្បាប់ឡើយ ។

៨. រាល់លិខិតជូនដំណឹង ឬលិខិតឆ្លើយឆ្លងផ្សេងៗទៀត (ដែលត្រូវហៅកាត់រួមគ្នាថា "លិខិតជូនដំណឹង") ដែលត្រូវផ្តល់ ឬធ្វើឡើងស្របតាមលិខិតធានានេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវដាក់អាសយដ្ឋានបញ្ជូនទៅបុគ្គល ដូចមានបញ្ជាក់ខាងក្រោម ដោយត្រូវប្រគល់ផ្ទាល់ដៃ ឬតាមអ្នករត់សំបុត្រ ។ រាល់លិខិតជូនដំណឹង ត្រូវបានចាត់ទុកថា បានប្រគល់ ៖

(ក). ពេលបានប្រគល់ផ្ទាល់ដៃ, ឬ

(ខ). នៅពេលប្រគល់ ដោយមានការកត់ត្រាត្រឹមត្រូវ និងមានការបានទទួល ដោយអ្នកផ្ញើឯកសារដែលមានការទទួលស្គាល់ជាអន្តរជាតិ បញ្ជូនទៅភាគីទទួល នៅអាសយដ្ឋានដូចខាងក្រោម (ឬក៏អាសយដ្ឋានដទៃទៀត ដែលភាគីនោះ អាចបញ្ជាក់តាមរយៈលិខិតជូនដំណឹង ឱ្យទៅភាគីប្រគល់លិខិត នៅអាសយដ្ឋាន ឬលេខទូរសារ ចែងខាងក្រោម) ៖

សម្រាប់ អ្នកធានា ៖

ជូនចំពោះ	៖ ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អាសយដ្ឋាន	៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្លូវលេខ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរសារលេខ	៖ +៨៥៥ ២៣ ៤២៧ ៧៩៨

សម្រាប់ ក្រុមហ៊ុន ៖

ជូនចំពោះ	៖ ប្រធានក្រុមហ៊ុន ហាយដ្រូ ផៅវ័រ ឡូវើរ សេសាន្ត២
អាសយដ្ឋាន	៖ លេខ ២៤៦, មហាវិថីព្រះមុនីវង្ស, សង្កាត់បឹងរាំង, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ,

ព្រះរាជាណាចក្រកម្ពុជា
ទូរសារលេខ ៖ +៨៥៥ ២៣ ៤២៦ ៤១៥

ឬក៏អាសយដ្ឋានផ្សេងទៀត ដែលភាគីណាមួយ អាចជូនដំណឹងឱ្យភាគីមួយទៀត ។

៩. អ្នកជានាមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតជានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពីក្រុមហ៊ុនឡើយ ហើយក្រុមហ៊ុនមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតជានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពីអ្នកជានាឡើយ ។ ថ្វីបើមានបញ្ញត្តិក្នុងវាក្យខណ្ឌមុននេះក្តី សម្រាប់គោលបំណងអភិវឌ្ឍន៍ ឬការផ្តល់ហិរញ្ញប្បទានអចិន្ត្រៃយ៍ដល់គម្រោង ក្រុមហ៊ុនអាចប្រគល់សិទ្ធិ ឬបង្កើតការជានាផលប្រយោជន៍ ចំពោះសិទ្ធិ និងផលប្រយោជន៍ ក្នុង និងចំពោះលិខិតជានានេះ សម្រាប់ជាប្រយោជន៍ដល់អ្នកឱ្យខ្ចីប្រាក់ ។ លិខិតជានានេះ ត្រូវជាចំណងផ្លូវច្បាប់ និងមានប្រសិទ្ធភាព ជាប្រយោជន៍ដល់អ្នកជានា និងក្រុមហ៊ុន ព្រមទាំងអ្នកបន្តវេន និងអ្នកទទួលសិទ្ធិស្របច្បាប់ របស់ភាគីនីមួយៗ ។

១០. សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជានា និងក្រុមហ៊ុន ក្រោម ឬអនុលោមតាមលិខិតជានានេះ ត្រូវបានគ្រប់គ្រងដោយ និងបកស្រាយតាមច្បាប់នៃប្រទេសអង់គ្លេស ដែលនឹងត្រូវជាច្បាប់គ្រប់គ្រងមជ្ឈត្តកនិច្ឆ័យផងដែរ ។

១១. ប្រសិនបើមានវិវាទ ឬការខ្វែងគំនិតណាមួយកើតឡើង តាមរូបភាពណាក៏ដោយ ឬពាក់ព័ន្ធនឹងលិខិតជានានេះ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីភាគីមួយ បានទទួលសេចក្តីជូនដំណឹងពីភាគីមួយទៀត ស្តីពីការកើតឡើងនៃវិវាទ អ្នកជានា និងក្រុមហ៊ុន ត្រូវដោះស្រាយវិវាទនោះ តាមរយៈការពិភាក្សាជាមិត្តភាព ។ ប្រសិនបើមិនអាចដោះស្រាយបានតាមរយៈការពិភាក្សាជាមិត្តភាពទេ ត្រូវបញ្ជូនវិវាទនោះ ទៅមជ្ឈមណ្ឌលមជ្ឈត្តកនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ ដើម្បីដោះស្រាយស្របទៅតាមវិធាន នៃមជ្ឈមណ្ឌលមជ្ឈត្តកនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ ។ ប្រសិនបើមានភាពមិនស្របគ្នាដោយអន្លើ រវាងបញ្ញត្តិនេះ និងវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តកនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ បញ្ញត្តិនេះត្រូវមានប្រសិទ្ធភាព ។ សេចក្តីសម្រេច ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយគឺជាសេចក្តីសម្រេចស្ថាពរ ជាសេចក្តីសន្និដ្ឋាន និងជាចំណងផ្លូវច្បាប់ទៅលើអ្នកជានា និងក្រុមហ៊ុន និងអាចយកមកអនុវត្ត នៅក្នុងតុលាការកម្ពុជាណាមួយ ដែលមានយុត្តាធិការធ្វើឱ្យសេចក្តីសម្រេចនោះ អនុវត្តបាន ។ ភាគីទាំងពីរត្រូវទទួលយក និងអនុវត្តសេចក្តីសម្រេចនោះ ហើយភាគីនីមួយៗ ត្រូវទម្លាក់ចោលដោយឥតលក្ខខណ្ឌនូវសិទ្ធិណាមួយ ដែលគេអាចមាន ដើម្បីតវ៉ាអំពីសុពលភាពនៃសេចក្តីសម្រេចនោះ ឬយុត្តាធិការនៃតុលាការមជ្ឈត្តកនិច្ឆ័យនោះ ដើម្បីធ្វើសច្ចការឯកសារយោងណាមួយ ទៅមជ្ឈត្តកនិច្ឆ័យ ដែលលិខិតជានានេះមានប្រសិទ្ធភាពអនុវត្ត ។ រាល់ការទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តកនិច្ឆ័យ ត្រូវធ្វើជាប្រាក់ដុល្លារអាមេរិក ។ ចំណាយលើមជ្ឈត្តកនិច្ឆ័យ ត្រូវទូទាត់ដោយភាគីដែលចាញ់ក្តី លើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយតុលាការមជ្ឈត្តកនិច្ឆ័យនោះ ។ ភាគីដែលទទួលខុសត្រូវ

ទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវបង់ការប្រាក់តាមអត្រា LIBOR បូក ៣% (បីភាគរយ) ទៅឱ្យភាគីម្ខាងទៀត នៅពេលទទួលសេចក្តីសម្រេចពីមជ្ឈត្តវិនិច្ឆ័យនោះ ដោយគិតចាប់ពីកាលបរិច្ឆេទត្រូវទូទាត់ រហូតដល់ថ្ងៃទូទាត់រួច ។

១២. ពាក្យសរសេរជាអក្សរធំ ដែលបានប្រើ ប៉ុន្តែពុំមានកំណត់ន័យក្នុងលិខិតធានានេះ ត្រូវមានន័យដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនី PPA ។

១៣. ប្រសិនបើបញ្ញត្តិណាមួយ ឬច្រើន ក្នុងលិខិតធានានេះ ត្រូវបានរកឃើញថា គ្មានសុពលភាព ខុសច្បាប់ ឬគ្មានតម្លៃតាមផ្លូវច្បាប់ បញ្ញត្តិទាំងនោះ ត្រូវរក្សាតម្លៃដែលអនុញ្ញាតដោយច្បាប់ ហើយភាពគ្មានសុពលភាព ភាពខុសច្បាប់ ឬភាពគ្មានតម្លៃតាមផ្លូវច្បាប់នោះ ពុំមានឥទ្ធិពលដល់សុពលភាព នៃបញ្ញត្តិផ្សេងទៀត នៃលិខិតធានានេះឡើយ ។ តាមការឯកភាពគ្នាទៅវិញទៅមក គ្មានការទូទាត់កាត់កង ការប្តឹងទាមទារទៅវិញទៅមក ការបន្ធូរបន្ថយ ឬការបន្ថយកាតព្វកិច្ចណាមួយ ដែលអ្នកធានាមាន ឬអាចមានចំពោះក្រុមហ៊ុន ត្រូវតែមានសម្រាប់អ្នកធានា សម្រាប់តតាំងជាមួយក្រុមហ៊ុន ទាក់ទងនឹងកាតព្វកិច្ចណាមួយ របស់អ្នកធានាចំពោះក្រុមហ៊ុន ក្រោមលិខិតធានានេះឡើយ ។

១៤. លិខិតធានានេះ ត្រូវផុតសុពលភាពនៅពេលបញ្ចប់ IA និង PPA ប្រសិនបើគ្មានការទាមទារ ហើយនៅរក្សាការធានានេះដដែល ករណីមានសំណើសុំជាលាយលក្ខណ៍អក្សរណាមួយ ពីក្រុមហ៊ុនជូនមកអ្នកធានា ស្របតាមលិខិតធានានេះ ដែលត្រូវតែទទួលបានដោយអ្នកធានាមុនពេលនោះ ។

១៥. លិខិតធានានេះ នឹងចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្ត បន្ទាប់ពីទទួលបានការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា ។

សូមលោកប្រធាន មេត្តាទទួលនូវការរាប់អាន ពីខ្ញុំ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន ៖
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-អគ្គិសនីកម្ពុជា
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
№ 002 MEF/...............

Phnom Penh, December 12, 2012

GOVERNMENT GUARANTEE OF PAYMENTS

To: Hydro Power Lower Sesan 2 Co., Ltd.
Address : No. 246, Preah Monivong Blvd., Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
Facsimile : +855 23 426 415
Attention : Chairman, Hydro Power Lower Sesan 2 Co., Ltd.

We refer to:

(A) Delegation of Full Power No. 120 D.F.P. dated 13 November 2012 by Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia. (Please see Attachment 1).

(B) The Implementation Agreement ("IA") dated 26 November 2012, entered between the Royal Government of Cambodia ("RGC") represented by Minister of Ministry of Industry, Mines and Energy ("MIME") and Hydro Power Lower Sesan 2 Co., Ltd. (the "Company").

(C) ELECTRICITÉ DU CAMBODGE, a wholly state-owned limited liability enterprise incorporated by Royal Decree No. CHS/RD/0396/10 of the RGC dated 9 March 1996, with its principal office located at Street 19, Wat Phnom, Daun Penh District, Phnom Penh, in the Kingdom of Cambodia, including its successors and permitted assignees ("EDC") has entered into a Power Purchase Agreement ("PPA") with the Company dated 26 November 2012.

(D) The Royal Government of Cambodia agreed to provide: (i) a guarantee on power purchase in the event of non-payment by EDC, and (ii) a guarantee on the payment on the termination in accordance with the PPA and/or IA and in the event that the Company is unable to operate the Project arising from the Political Force Majeure Events.

(E) It is a requirement of the Implementation Agreement in accordance with its Section 5.3, the Minister of Economy and Finance on behalf of Royal Government of Cambodia (the "Guarantor") has agreed to enter into this Guarantee of the payment obligations of EDC/MIME under the PPA and IA.

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

We hereby guarantee that:

1. The Guarantor hereby irrevocably and unconditionally guarantees and promises to pay to the Company any and every sum of money which is due and owed by MIME or EDC to Company under the IA or PPA that MIME or EDC has failed to pay in accordance with the terms of the IA or PPA (the "Guarantee").

2. This Guarantee shall be a continuing security and accordingly, shall extend to cover the balance due to the Company at any time from MIME or EDC under the IA or PPA, notwithstanding any notice of termination or the liquidation or other incapacity or any change in Royal Decree concerning MIME or EDC or in the name or style thereof or any settlement of account or other matter whatsoever.

3. Before taking steps to enforce this Guarantee and demand payment from the Guarantor, the Company shall be obliged only to make demand in writing for payment from MIME or EDC. After sixty (60) days from the date of the invoice(s) as specified in Section 8.7.1 of the PPA or any payment demand from the Company to MIME being received by EDC or MIME, the Company may notify the Guarantor in writing that payment from MIME or EDC is overdue and make a demand for payment from the Guarantor under this Guarantee, and the Guarantor shall make payment within thirty (30) Days. The Guarantor's late payment hereunder shall bear interest at an annual rate of LIBOR plus 3% (three percent). And no demand made by the Company hereunder shall prejudice or restrict the right of the Company to make further or other demands against any other unpaid invoice(s).

   All sums payable by the Guarantor under this Guarantee shall be fully paid to the bank account designated by the Company in the Kingdom of Cambodia in US Dollars to the Company.

4. Any demand for payment made pursuant to this Guarantee shall be made by courier or in person by a duly authorized officer of the Company at the Guarantor's offices and shall be accompanied by a certificate signed by a duly authorized officer of the Company stating, without the obligation to substantiate, that:

   "We hereby certify that:

   (1) Hydro Power Lower Sesan 2 Co., Ltd. (the "Company") is making this demand on the Ministry of Economy and Finance (the "Guarantor") in the amount of U.S. Dollars ----------------- [insert amount] in accordance with Section 1 of the Guarantee dated ---------------- between the Guarantor and the Company;

   (2) The amount specified above is due and payable by EDC/MIME under the PPA/IA between the Company and EDC/MIME and no part of the amount specified above is the subject of a dispute between the EDC/MIME and the Company;

   (3) Demand in writing for payment from MIME/EDC has been made;

   (4) Such amount, on the date hereof, remains unpaid by MIME/EDC."

5. The Guarantor represents and warrants that, as of the date hereof:

- The Guarantor has full power, authority, and legal right to incur the obligation, to execute and deliver, and to perform and observe the terms and provisions of this Guarantee.
- This Guarantee constitutes legal, valid, binding, and enforceable obligations of the Guarantor in accordance with its terms.
- All necessary action has been taken, and all approvals required have been obtained, under the Laws of the Kingdom of Cambodia to authorize the execution, delivery, and performance of this Guarantee.
- The obligations and covenants of the Guarantor in this Guarantee constitute unconditional obligations of the Guarantor, for the performance of which the full faith and credit of the Guarantor is pledged.
- The Guarantor unconditionally and irrevocably agrees that the execution, delivery, and performance by it of this Guarantee constitute commercial acts rather than public or governmental acts and such Guarantee constitutes its unconditional and irrevocable direct obligation.
- Should any proceedings be brought against the Guarantor or its assets in any jurisdiction in relation to this Agreement, no immunity from such proceedings shall be claimed by or on its behalf or with respect to its assets which it now has or may acquire in the future.

6. This Guarantee shall remain in full force and effect from the Construction Commencement Date until the termination of the term of the IA or PPA and for so long thereafter as any amount owed to the Company by EDC in connection with such term is or may be outstanding.

7. No failure or delay by the Company to exercise any right or remedy under this Guarantee shall constitute a waiver of that right or remedy. No single or partial exercise of any right or remedy shall preclude any other or further exercise thereof or the exercise of any other right or remedy. No waiver by the Company shall be effective unless it is in writing. The rights and remedies of the Company provided by this Guarantee are cumulative and not exclusive of any rights or remedies provided by law.

8. All notices or other communications (together "Notices") to be given or made hereunder shall be in writing, shall be addressed for the attention of the person indicated below and shall be delivered personally or by courier. All Notices shall be deemed delivered:

   (a) when presented personally, or

   (b) upon the day of duly recorded and receipted delivery by a recognized international document courier, addressed to the receiving Party, at the address indicated below.

(or such other address as such Party may have specified by notice delivered to the delivering Party at its address or facsimile number specified below).

The address for service of Notice shall be:

For the Guarantor:

Attention	: Minister, Ministry of Economy and Finance
Address	: Ministry of Economy and Finance Street No. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Kingdom of Cambodia
Facsimile	: +855 23 427 798

For the Company:

Attention	: Chairman, Hydro Power Lower Sesan 2 Co., Ltd
Address	: No. 246, Preah Monivong Blvd., Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
Facsimile	: +855 23 426 415.

or such other addresses as either Party may have notified to the other Party.

9. The Guarantor shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Company, and the Company shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Guarantor. Notwithstanding the provision of the immediately preceding sentence, for the purpose of development or permanent financing of the Project, the Company may assign or create a security interest over its rights and interests in and to this Guarantee in favor of the Lenders. This Guarantee shall be binding upon and inure to the benefit of the Guarantor and the Company and the respective successors and permitted assignees of each Party.

10. The rights and obligations of the Guarantor and the Company under or pursuant to this Guarantee shall be governed by and construed according to the Laws of England, which shall also be the procedural law governing any arbitration.

11. If there is any dispute or difference of any kind whatsoever arising out of or in connection with this Guarantee, the Guarantor and the Company shall attempt for a period of thirty (30) days after the receipt by one Party of a notice from the other Party of the existence of the dispute to settle such dispute through mutual amicable discussions. Should such dispute can't be resolved through mutual amicable discussions, then it shall be submitted to the Singapore International Arbitration Center for arbitration in accordance with the arbitration rules of the Singapore International Arbitration Center. And if there are discrepancies between this clause and the rules of the Singapore International Arbitration Center, this clause shall govern. The award rendered shall be in writing and shall be final, conclusive and binding upon the Guarantor and the Company and award thereon may be entered in any Cambodian court having jurisdiction for its enforcement. Such Parties shall execute and perform the award and each Party hereby irrevocably waives any right it may have to contest the validity of such award or the jurisdiction of the arbitration tribunal to hear any

reference to arbitration to which this Guarantee applies. Any payment under arbitration award shall be payable in U.S. Dollars. The costs of arbitration shall be borne by the losing Party, unless otherwise determined by the arbitration tribunal. The Party that is responsible to pay an arbitration award shall pay interest at a rate of LIBOR plus 3% (three percent) to the other Party in receipt of such arbitration award from the due date for the payment of such award until the date of payment of such award.

12. The capitalized terms used but not defined in this Guarantee shall have the meanings given to them in the Power Purchase Agreement.

13. If one or more provisions contained in this Guarantee is held or found to be invalid, illegal, or unenforceable in any respect, the provision(s) shall be given effect to the extent permitted by law and the invalidity, illegality, or unenforceability of any provision shall not affect the validity of the remaining provisions of this Guarantee.
Subject to mutual agreement, no set-off, counterclaim, reduction, or diminution of any obligation that the Guarantor has or may have against the Company shall be available to the Guarantor against the Company in connection with any obligation of the Guarantor to the Company under this Guarantee.

14. This Guarantee shall expire upon the termination of the IA and PPA if no claim has been made and remains outstanding hereunder and any written demand made to us by the Company hereunder must therefore be received by us before that time.

15. This Guarantee shall become in full force and effect on its ratification by legislatures of the Kingdom of Cambodia.

Yours faithfully,

KEAT CHHON
Deputy Prime Minister,
Minister, Ministry of Economy & Finance

CC :
- Ministry of Royal Palace
- Secretariat of Senate
- Secretariat of National Assembly
- Council for the Development of Cambodia (CDC)
- Office of Council of Ministers
- Ministry of Foreign Affairs and International Cooperation
- Ministry of Industry, Mines, and Energy
- Cabinet of Samdech Akka Moha Sena Padei Techo, Prime Minister
- Electricite du Cambodge (EDC)
- File

ព្រះរាជក្រឹត្យ

នស/រកត/០៣១៣/២៤៨

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ដំឡើងឋានន្តរស័ក្តិជូនឯកឧត្តម **គឹម ហុង** ពីឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៣ ទៅឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

មាត្រា២ : សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

លេខ: ២២៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៣
អគ្គលេខា[illegible]ទី[illegible]រាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១៣/២៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ទ្រង់ប្រោសព្រះរាជទាន

ចំពោះ

ព្រះតេជគុណ ឯកឧត្តម អស់លោក លោកស្រី ជាមន្ត្រីរាជការ និងសប្បុរសជន ចំនួន ៧០ រូប
ដែលមានគុណបំណាច់យ៉ាងធំធេងក្នុងការបម្រើជាតិមាតុភូមិ

នូវ

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :
១- ឯកឧត្តម **ស៊ឹមតៃ** ២- លោក **ផុក តិរិទ្ធរិទ្ធ**

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :
១- ឯកឧត្តម **រស់ លន់** ២- លោក **ហែម ហឿន**
៣- លោក **ចៅ វន្ថា** ៤- លោក **ឡេង ណេរ៉ូ**
៥- លោក **ឃីក ជាតិ** ៦- លោក **រ័ត្ន ចាន់ណា**
៧- លោក **តេង រ័ត្ន** ៨- លោក **យឹម អូន**
៩- លោក **ហួន ថេង** ១០- លោក **យិន ចិន្តាវុឌ្ឍ**
១១- លោក **សេង សុជាតិ** ១២- លោក **ជូ សុផារណ្ណ**
១៣- លោក **ស៊ា ស៊ីម** ១៤- លោក **ឈុន ហួរ**

គ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :
- ឯកឧត្តម **នូ នឹម**

ឃ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :
១- ព្រះតេជគុណ **ថេង សុធា** ២- ឯកឧត្តម **ម៉ក់ ជឿន**
៣- លោក **វង ម៉ន** ៤- លោក **យូ សុខ**

ង-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :
- លោក **អ៊ុន សុផានណារិទ្ធ**

ច-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** :
១- លោក **ញ៉ឹក ប៊ុនលេខ** ២- លោក **សឿង ឌី**
៣- លោក **ស៊ូ ស៊ីង** ៤- លោក **សូ ទីរ៉ា**

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

ឆ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ សេនា :

១- លោក **ឃុំង វណ្ណរេត** ២- លោក **ម៉ែន នរៈឌុច**

៣- លោក **ណុប សាវ៉ាត** ៤- លោក **ហយ ស៊ីថា**

៥- លោក **ប៊ិង វណ្ណា** ៦- លោក **កែវ រុណា**

៧- លោក **ឡឺ ប៉ូលីន** ៨- លោក **តឹក ចាន់ថា**

៩- លោក **នៅ សុមនា** ១០- លោក **ហ៊ុម សារ៉ុន**

១១- លោក **ឱន ប្រសិទ្ធិ** ១២- លោក **ជាន សុខចេង**

១៣- លោក **ហែម សោភ័ណ្ឌ** ១៤- លោក **សេង ចេង**

១៥- លោក **លឹម ជាវឡាយតារា**

ជ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

១- លោក **សាយ សំណាង** ២- លោក **អ៊ុក ដារ៉ាន់**

៣- លោក **ទួច អូន** ៤- លោក **រស់ សីកូមុនី**

៥- លោក **គុណ ជាស៊ុន** ៦- លោក **កែវ នន់**

៧- លោក **នេត ឃ្លោក** ៨- លោក **ហម ឈាន**

៩- លោក **ឡាង ឡុន** ១០- លោក **សំ សុភាន**

១១- លោកស្រី **ជា ស៊ីថា** ១២- លោកស្រី **ជា សំអន**

១៣- លោក **ហែម សុភាព** ១៤- លោក **ឈឹម សាវឿន**

១៥- លោក **ចាន់ សារឹម** ១៦- លោក **ជុត ជាតិ**

១៧- លោក **យង់ ចាន់ទាសនា** ១៨- លោក **និន ដារ៉ា**

១៩- លោក **អ៊ុំ ប៊ុញ** ២០- លោក **អ៊ុន ភាថន**

២១- លោក **រី សារ៉ាត់** ២២- លោក **សុខ រី**

២៣- លោក **សុខ សុផល**

ឈ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** :

- លោក **កែវ រុណា**

ញ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** :

១- លោក **ស្វាយ ថន** ២- លោក **សោម ខុន**

៣- លោក **ឆេង ឌឹម** ៤- លោក **យឹម អ៊ាត**

៥- លោក **ថាច សុខ**

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

ព្រស.១៣០៣.២៧២

លេខៈ ៣២៩ ប.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ២០១៣

អគ្គលេខាធិការរងទីស្ដីការរាជរដ្ឋាភិបាល

[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១៣/៧៣០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ព្រះតេជគុណ ឯកឧត្តម លោកជំទាវ ឧកញ៉ា អស់លោក លោកស្រី ជាមន្ត្រីរាជការ
និងសប្បុរសជន ចំនួន ៦៦ រូប ដែលមានគុណបំណាច់យ៉ាងធំធេងក្នុងការបម្រើជាតិមាតុភូមិ

នូវ

ក-គ្រឿងឥស្សរិយយស **ជាតូបការ :**

១-លោកជំទាវ **អោម នាង** ២-ឯកឧត្តម **លឹម ហាវធី**

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

១-ព្រះសិរីវិសុទ្ធិត្ថេរ **ជិន ជ្រឹន** ២-ព្រះបវរមុនី **ឈិត សុផៃ**
៣-ព្រះសច្ចវរោ **ជុំ ភន** ៤-ព្រះវិរិយៈធម្មោ **ចឿក ម៉ុនចឿន**
៥-ឯកឧត្តម **សេន សុវណ្ណ** ៦-ឯកឧត្តម **ទូច ស៊ុនណារី**
៧-លោកជំទាវ **ម៉ិន កនិកា** ៨-ឧកញ៉ា **ឡាវ ហេង**
៩-លោកជំទាវ **លឹម សុខលី** ១០-លោក **ស៊ីវ សារឿន**
១១-លោក **ពាង ផារ័ត្ន** ១២-លោក **ឌិន វ៉ាន់នី**
១៣-លោក **នៅ ពិសិដ្ឋ** ១៤-លោក **ស៊ិន សុភា**
១៥-លោកស្រី **អ៊ុង សុវណ្ណនី** ១៦-លោកស្រី **កោត ចន្ថេត**
១៧-លោក **ឡុង ឆូ** ១៨-ព្រឹទ្ធាចារ្យ **លឹម តាយសេង**
១៩-លោក **សោម ស៊ីណាត** ២០-លោក **វ៉េន សំអូន**

គ-គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈនារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

១-ឯកឧត្តម **តាំង ឈុនធី** ២-លោកជំទាវ **ខៀវ ប៊ូរី**
៣-លោក **ឈួន ហៃ** ៤-លោក **សំរិទ្ធ សុខហួន**
៥-លោក **អ៊ុង លីសៀក**

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ឃ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១-ព្រះគ្រូលក្ខណោ **គង់ លឹម** ២-វរសេនីយ៍ឯក **កែប ម៉ារ៉ាទី** អត្តលេខ **០២៦៥០៧**

៣-លោក **ហេង រស្មី** ៤-លោក **គិញ ទើត**

៥-លោក **ម៉ារ យ៉ារិទ្ធិ** ៦-វរសេនីយ៍ទោ **ឡៅ សុវណ្ណារិទ្ធ** អត្តលេខ **០១២២៨៤**

៧-លោក **សយ រតនៈ** ៨-លោក **ឈិន ចាន់ទី**

៩-អនុសេនីយ៍ឯក **លឹម ហួត** អត្តលេខ **១៤៤៧៨១** ១០-វរសេនីយ៍ឯក **សេង រីន** អត្តលេខ **០២១០៤៤**

១១-ព្រះគ្រូមេត្តាប៉ាឡោ **ធឹម សឿត** ១២-លោក **ឃូ សុខចាន់**

១៣-លោក **លឹម សុផល** ១៤-លោក **តាច ប៊ុនថេង**

ង-គ្រឿងឥស្សរិយយស **សេនាជ័យសិទ្ធ** :

១-ឧត្តមសេនីយ៍ត្រី **ហង្ស សារិទ្ធិ** អត្តលេខ **០០៣២៥១** ២-វរសេនីយ៍ត្រី **ស ប៊ុនស៊ៀង** អត្តលេខ **១៩៧៣៩២**

៣-លោកស្រីអនុសេនីយ៍ឯក **សៀ គឹមហ៊ាន** អត្តលេខ **០៣៩១២២**

ច-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១-ព្រះបមុត្តោ **មួត ទិណោ** ២-ព្រះវីរិយៈចិត្តោ **នុំ សុវណ្ណមុនី**

៣-លោក **ឈិន ប៊ុណ្ណា** ៤-អនុសេនីយ៍ត្រី **ហួត សីហា** អត្តលេខ **៥៨១១១**

៥-លោក **ឈុំ សុវណ្ណ** ៦-លោក **មាស សន**

៧-លោក **ពិត សារិត** ៨-លោក **នាក់ គយ**

៩-លោក **វណ្ណ ឌុច** ១០-លោក **ម៉ាត់ ត្រីយ៉ា**

១១-លោក **ព្រឿន ចំណាន**

ឆ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១-វរសេនីយ៍ឯក **ពេជ្រ លី** អត្តលេខ **០១៤៦១៣** ២-លោក **ឧច សុវណ្ណ**

៣-កញ្ញា **ហុក និព្វកេសរា** ៤-លោក **ហុក និព្វរតា**

៥-លោក **ជា រ៉ាទី** ៦-លោក **ឈិត ហាច**

៧-លោក **អែម សុណាន់** ៨-លោក **ជា ដែប**

៩-លោក **ប៉ែន សុវណ្ណថាច** ១០-លោក **លាំង គន្ធី**

១១-អនុសេនីយ៍ឯក **ជា បូរ៉ា** អត្តលេខ **៦៧០៦៤**

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣៧៤.១៣០៣.២៣៣

លេខៈ ២៦៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១៣

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១៣/២៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ០៧រូប ដែលមានគុណបំណាច់ និងស្នាដៃល្អ ដោយបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា ស្ថិតនៅវត្តពោធិវ័ន សង្កាត់ស្ពោរ ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ

នូវ

១- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ៖

- ឯកឧត្តម **ខូច វីរៈឫទ្ធិ**
- លោក **ថាន រដ្ឋរិទ្ធិ**

២- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៖

- ព្រះតេជគុណ **ព្រហ្ម សុភី**
- លោកជំទាវ **សុទ្ធ ធី**
- ឧបាសិកា **អ៊ឹង តាំងគួយ**
- ឧបាសិកា **សុខ ប៊ុណ្ណារី**
- លោក **យូ លីសេង**

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៣

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣៩៦.១៣០៣.២៣៤

លេខ ២៣០ ច.ល
ដើម្បីចម្លងចែកចាយ
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមីនា ឆ្នាំ២០១៣
អគ្គលេខាធិការ [illegible]
សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១៣/២៣៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ប្តូរប្រភេទក្របខ័ណ្ឌ ស្របតាមឧបនិស្ស័យមុខតំណែង ជូនមន្ត្រីរាជការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន ០១ រូប ពីមន្ត្រីក្នុងឋានន្តរស័ក្តិ នាយក្រមការ នៃក្របខ័ណ្ឌក្រមការ ទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលមន្ត្រីរាជការ ក្នុងឋានន្តរស័ក្តិ អនុមន្ត្រី ជាករណីពិសេស :

ល.រ	គោត្តនាម និង នាម	ភេទ	ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និង ថ្នាក់	
			ចាស់	ស្នើសុំ
១	ព្រំ វណ្ណៈ	ប	ខ.១.២	ក.៣.៧

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

៣៩០. ១៣០៣. ២៣៧

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

លេខ: ៤៣១ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រីរាជរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១៣/២៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

តែងតាំង :

១- លោក លាង ច័ន្ទមុនី
២- លោក អ៊ុក គឹមសាន
៣- លោក ទ្រី ដាលួច

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣៩៧.១៣០៣.២៧៥

លេខ ២៣១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១៣
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល
សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១៣/២៣៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៥២ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១១ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : កាត់ផ្ទៃដីទំហំ **៦៤៧,៤០** ហិកតា ពីរមណីយដ្ឋានប្រាសាទព្រះវិហារ ដែលកំណត់ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៥២ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១១ ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

ចរទស.១៣០៣.២៤១

លេខ: ៤២៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១៣
អគ្គលេខា[illegible]ទីរាជរដ្ឋាភិបាល
ស៊ុយ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

បែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៥១ អនក្រ.បក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះមានគោលបំណងបង្កភាពងាយស្រួលនិងឆាប់រហ័សក្នុងការស្វែងរកទីតាំងផ្លូវនៅលើផែនទីតំបន់ភូមិសាស្ត្រផ្លូវថ្នល់ និងធានារក្សាឱ្យបានច្រើនជាអតិបរមានូវអត្តសញ្ញាណលេខផ្លូវ និងឈ្មោះផ្លូវសំខាន់ៗពីមុនដែលធ្លាប់ប្រើប្រាស់កន្លងមក ព្រមទាំងបង្កភាពងាយស្រួលក្នុងការធ្វើផែនការជួសជុល កែលម្អ និងថែទាំផ្លូវថ្នល់។

មាត្រា ២.-

អនុក្រឹត្យនេះមានគោលដៅដូចតទៅៈ

- រៀបចំប្រព័ន្ធដាក់លេខផ្លូវថ្មីដើម្បីបំពេញបន្ថែមលើតម្រូវការចាំបាច់ ឆ្លើយតបទៅនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់
- បែងចែកតំបន់ភូមិសាស្ត្រផ្លូវថ្នល់
- កំណត់នីតិវិធីក្នុងការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងកែប្រែឈ្មោះផ្លូវឬលេខផ្លូវឱ្យមានការឯកភាពគ្នានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៣.-

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែផ្លូវល្បឿនលឿន ដែលត្រូវកំណត់ដោយបទប្បញ្ញត្តិដោយឡែក។

មាត្រា ៤.-

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅៈ

ឈ្មោះផ្លូវ សំដៅដល់ឈ្មោះផ្តល់ឱ្យជាផ្លូវការ ដែលប្រើប្រាស់សម្រាប់គោលបំណងសម្គាល់ទីតាំងផ្លូវឬអាសយដ្ឋានផ្លូវក្នុងតំបន់ណាមួយជាក់លាក់។

លេខផ្លូវ សំដៅដល់លេខផ្តល់ឱ្យជាផ្លូវការ ដែលប្រើប្រាស់សម្រាប់គោលបំណងសម្គាល់ទីតាំងផ្លូវឬអាសយដ្ឋានផ្លូវក្នុងតំបន់ណាមួយជាក់លាក់។ លេខផ្លូវត្រូវដាក់តាមលេខរៀងពីតូចទៅធំ មានលក្ខណៈជាលេខសេសឬលេខគូ។

ផែនទីអាសយដ្ឋានផ្លូវ សំដៅដល់ផែនទីកំណត់បញ្ជាក់យ៉ាងច្បាស់លាស់អំពីឈ្មោះផ្លូវ និងលេខផ្លូវ ចំណុចចាប់ផ្តើមនិងចំណុចបញ្ចប់នៃផ្លូវនីមួយៗ ព្រមទាំងបរិក្ខារសំខាន់ៗនៃផ្លូវនីមួយៗផងដែរ។

អាសយដ្ឋានផ្លូវ សំដៅដល់ប្រព័ន្ធប្រើប្រាស់សម្រាប់បញ្ជាក់ទីតាំងអគារ ឬ[illegible]ន ឈ្មោះផ្លូវឬលេខច្រកផ្លូវចូលសំខាន់ៗ។

ផ្លូវថ្នល់ ហៅថាផ្លូវ សំដៅដល់ទំហំផ្លូវទាំងមូល រួមមានតួផ្លូវ ទ្រូងផ្លូវ ជាយផ្លូវឬចិញ្ចើមផ្លូវ ស្ពាន ស្ពានអាកាស ស្ពានរំលង ផ្លូវរូង និងកំពង់ចម្លងតភ្ជាប់ផ្លូវថ្នល់។

ផ្លូវជាតិ សំដៅដល់ផ្លូវដែលមានចរាចរណ៍ច្រើន៖

ក - ផ្លូវភ្ជាប់ចេញពីរាជធានីភ្នំពេញឆ្ពោះទៅកាន់ក្រុងនៃខេត្តនីមួយៗនៅទូទាំងប្រទេស។

ខ - ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ក្រុងនៃខេត្តមួយទៀត។

គ - ផ្លូវភ្ជាប់ចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ផ្លូវជាតិ។

ឃ- ផ្លូវបែកចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ក្រុងនៃខេត្ត។

ង - ផ្លូវបែកចេញពីផ្លូវជាតិ ឬផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយឆ្ពោះទៅកាន់តំបន់សំខាន់ៗ ដូចជាកំពង់ផែ ស្ថានីយរថភ្លើង អាកាសយានដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស រមណីយដ្ឋានទេសចរណ៍ ច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន តំបន់មានសក្តានុពលសេដ្ឋកិច្ចសំខាន់ៗផ្សេងទៀត។

ច - ផ្លូវសំខាន់ៗរបស់ជាតិ មានចរាចរណ៍ច្រើនដែលកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

ផ្លូវខេត្ត សំដៅដល់ផ្លូវដែលមានចរាចរណ៍មធ្យម៖

ក- ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ទីរួមស្រុក ខណ្ឌ។

ខ- ផ្លូវបែកចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ផ្លូវខេត្ត។

គ- ផ្លូវបែកចេញពីផ្លូវខេត្តឬផ្លូវក្រុង ឆ្ពោះទៅកាន់ទីរួមស្រុក ខណ្ឌ។

ឃ- ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ផ្លូវខេត្ត។

ង- ផ្លូវបែកចេញពីផ្លូវខេត្ត ឆ្ពោះទៅកាន់ផ្លូវខេត្ត។

ច- ផ្លូវបែកចេញពីផ្លូវខេត្តឬផ្លូវក្រុង ឬផ្លូវទីរួមស្រុកនៃខេត្ត ឆ្ពោះទៅកាន់តំបន់សំខាន់ៗ ដូចជាកំពង់ផែ ស្ថានីយរថភ្លើង អាកាសយានដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស រមណីយដ្ឋានទេសចរណ៍ ច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន តំបន់មានសក្តានុពលសេដ្ឋកិច្ចមធ្យមផ្សេងទៀត។

ផ្លូវរាជធានី ផ្លូវក្រុង និងផ្លូវទីរួមស្រុកនៃខេត្ត សំដៅដល់ផ្លូវថ្នល់ដែលស្ថិតនៅក្នុងបរិវេណភូមិសាស្ត្ររដ្ឋបាលរាជធានី ខេត្ត ដោយរួមមានទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងផ្លូវថ្មើរជើង។

ផ្លូវជនបទ សំដៅដល់៖

ក - ផ្លូវដែលភ្ជាប់ពីផ្លូវជាតិ ផ្លូវខេត្ត ឆ្ពោះទៅកាន់ក្រុង ទីរួមស្រុក ខណ្ឌ ទីប្រជុំជនឃុំ សង្កាត់ និងទៅភូមិ។

ខ - ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក ខណ្ឌ ឆ្ពោះទៅកាន់ក្រុង ទីរួមស្រុក ខណ្ឌ។

គ - ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក ខណ្ឌ ទៅទីប្រជុំជនឃុំ សង្កាត់។

ឃ- ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ ទៅទីប្រជុំជនឃុំ សង្កាត់។

ង - ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ ទៅភូមិ។

ច - ផ្លូវដែលភ្ជាប់ពីភូមិទៅភូមិ។

ឆ - ផ្លូវក្នុងភូមិ។/

ផ្លូវល្បឿនលឿន សំដៅដល់ផ្លូវសម្រាប់យានយន្តធ្វើចរាចរណ៍ មានបរិក្ខារចែកទ្រូងផ្លូវជាពីរចំណែកខុសទិសគ្នាឬចែកជាគន្លងផ្លូវ គ្មានកន្លែងផ្លូវប្រសព្វលើផ្ទៃរាបមួយឬត្រូវមានផ្លូវប្រសព្វតិចបំផុតក្នុងករណីចាំបាច់ និងបំពាក់គ្រប់គ្រាន់នូវបរិក្ខារផ្លូវថ្នល់ ដើម្បីធានាលំហូរចរាចរណ៍អត់ឈប់ សុវត្ថិភាព និងដើម្បីបន្ថយពេលវេលាធ្វើដំណើរ និងមានកន្លែងកំណត់សម្រាប់ឱ្យយានយន្តចេញនិងចូលផ្លូវល្បឿនលឿន។

សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ សំដៅដល់ក្រសួងទទួលបន្ទុកវិស័យផ្លូវថ្នល់និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានទទួលប្រតិភូកម្មអំណាចពីក្រសួងទទួលបន្ទុកវិស័យផ្លូវថ្នល់។

ជំពូកទី២
សមត្ថកិច្ចគ្រប់គ្រង

មាត្រា ៥.-

សមត្ថកិច្ចក្នុងការដាក់ឈ្មោះផ្លូវឬលេខផ្លូវនិងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ ត្រូវបានកំណត់ដូចខាងក្រោម៖

១ - ក្រសួងទទួលបន្ទុកវិស័យផ្លូវថ្នល់

- ក្រសួងសាធារណការនិងដឹកជញ្ជូនមានសមត្ថកិច្ចដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងកែប្រែឈ្មោះផ្លូវឬលេខផ្លូវដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន និងដាក់ឈ្មោះផ្លូវឬលេខផ្លូវផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន
- ក្រសួងអភិវឌ្ឍន៍ជនបទមានសមត្ថកិច្ចដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងកែប្រែឈ្មោះផ្លូវឬលេខផ្លូវដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន និងដាក់ឈ្មោះផ្លូវឬលេខផ្លូវផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

២ - រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានទទួលប្រតិភូកម្មអំណាចពីក្រសួងទទួលបន្ទុកវិស័យផ្លូវថ្នល់ មានសមត្ថកិច្ចដាក់ឈ្មោះផ្លូវឬលេខផ្លូវនិងកែប្រែឈ្មោះផ្លូវឬលេខផ្លូវក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

មាត្រា ៦.-

សមត្ថកិច្ចក្នុងការដាក់ឈ្មោះផ្លូវឬលេខផ្លូវនិងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ ដូចមានចែងក្នុងមាត្រា៥ខាងលើ ត្រូវបង្កើតគណៈកម្មាធិការសិក្សាស្រាវជ្រាវនិងរៀបចំបញ្ជីផ្លូវដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ដើម្បីដាក់ស្នើសុំគោលការណ៍ឯកភាពពីរាជរដ្ឋាភិបាលក្នុងការដាក់ឈ្មោះផ្លូវឬលេខផ្លូវនិងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ។ ដោយឡែក ចំពោះផ្លូវទើបសាងសង់ថ្មី ត្រូវស្នើសុំដាក់ឈ្មោះផ្លូវឬលេខផ្លូវមុនពេលចាប់ផ្តើមសាងសង់ឬក្រោយពេលសាងសង់រួចរាល់ជាស្ថាពរ។

គណៈកម្មាធិការសិក្សាស្រាវជ្រាវនិងរៀបចំបញ្ជីផ្លូវ ត្រូវបង្កើតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យផ្លូវថ្នល់។

គណៈកម្មាធិការសិក្សាស្រាវជ្រាវនិងរៀបចំបញ្ជីផ្លូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបង្កើតដោយដីការបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

ជំពូកទី៣
ការកំណត់តំបន់ភូមិសាស្ត្រផ្លូវថ្នល់

មាត្រា ៧.-

តំបន់ភូមិសាស្ត្រផ្លូវថ្នល់ ត្រូវបានកំណត់និងបែងចែកតាមខ្សែបន្ទាត់ទន្លេមេគង្គនិងទន្លេសាប ជា៣(បី)តំបន់ ដូចខាងក្រោម៖

១- តំបន់១ ស្ថិតនៅទិសនិរតី ក្នុងចន្លោះទន្លេមេគង្គក្រោមនិងទន្លេសាប តាងដោយលេខ"១"។

២- តំបន់២ ស្ថិតនៅទិសពាយ័ព្យ ក្នុងចន្លោះទន្លេមេគង្គលើនិងទន្លេសាប តាងដោយលេខ "២"។

៣- តំបន់៣ ស្ថិតនៅទិសបូព៌ា ក្នុងចន្លោះទន្លេមេគង្គលើនិងទន្លេមេគង្គក្រោម តាងដោយលេខ"៣"។

ការកំណត់តំបន់ភូមិសាស្ត្រផ្លូវថ្នល់ខាងលើនេះ ប្រើប្រាស់សម្រាប់តែវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ប៉ុណ្ណោះ។ ផែនទីតំបន់ភូមិសាស្ត្រផ្លូវថ្នល់មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

មាត្រា ៨.-

ផ្លូវថ្នល់ដែលទទួលបានការឯកភាពជាគោលការណ៍ពីរាជរដ្ឋាភិបាល ដើម្បីឱ្យដាក់ឈ្មោះផ្លូវឬដាក់លេខផ្លូវហើយ ត្រូវរៀបចំដាក់បញ្ចូលទៅក្នុងផែនទីតំបន់ភូមិសាស្ត្រផ្លូវថ្នល់ និងត្រូវបោះពុម្ពសម្រាប់បម្រើឱ្យវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ព្រមទាំងត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ។

មាត្រា ៩.-

ផែនទីតំបន់ភូមិសាស្ត្រផ្លូវថ្នល់ត្រូវធ្វើការត្រួតពិនិត្យនិងរៀបចំជាថ្មីឡើងវិញក្នុងរយៈពេលយ៉ាងយូរ៥(ប្រាំ)ឆ្នាំម្តង និងត្រូវបោះពុម្ពផ្សព្វផ្សាយជាសាធារណៈក្រោយពីបានទទួលការឯកភាពពីរាជរដ្ឋាភិបាល។

ការបញ្ចូលបណ្តាញផ្លូវថ្មីទៅក្នុងផែនទីតំបន់ភូមិសាស្ត្រផ្លូវថ្នល់ និងការបោះពុម្ពផែនទីតំបន់ភូមិសាស្ត្រផ្លូវថ្នល់ ត្រូវធ្វើឡើងដោយគណៈកម្មការជំនាញមួយដែលមានការចូលរួមពីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលរាជធានី ខេត្ត និងដែលត្រូវបង្កើតដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

មាត្រា ១០.-

ផែនទីតំបន់ភូមិសាស្ត្រផ្លូវថ្នល់ អាចផ្តល់ជូនតាមការស្នើសុំរបស់ក្រសួង ស្ថាប័ននានានិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយឥតគិតថ្លៃក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ។

ជំពូកទី៤
គោលការណ៍និងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ
និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ
ផ្នែកទី១
គោលការណ៍នៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ
និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ

មាត្រា ១១.-

ការដាក់ឈ្មោះផ្លូវឬលេខផ្លូវនិងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

១- ត្រូវកំណត់ទីតាំងនិងចម្ងាយផ្លូវឱ្យបានជាក់លាក់ ទោះបីជាស្ថិតក្នុងស្ថានភាពភូមិសាស្ត្រផ្សេងៗពីគ្នាក៏ដោយ។

២- ត្រូវឱ្យមាននិរន្តរភាពឬភាពតៗគ្នា គឺត្រូវដាក់ឈ្មោះផ្លូវឬលេខផ្លូវនីមួយៗឱ្យរត់តាមទិសដៅតែមួយមានឈ្មោះផ្លូវឬលេខផ្លូវតែមួយក្នុងរយៈចម្ងាយផ្លូវទាំងមូល ឬពីចំណុចចាប់ផ្តើមរហូតដល់ចំណុចបញ្ចប់នៃផ្លូវនីមួយៗ។

មាត្រា ១២.-

ការដាក់ផ្លាកឈ្មោះផ្លូវឬលេខផ្លូវ ត្រូវធានាឱ្យមានភាពច្បាស់លាស់ និងស្របតាមស្តង់ដាបច្ចេកទេសដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យផ្លូវថ្នល់ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមមាត្រា៥នៃអនុក្រឹត្យនេះ។

មាត្រា ១៣.-

ក្នុងករណីមានការកែប្រែឈ្មោះផ្លូវឬលេខផ្លូវថ្មីដោយសារការវិវឌ្ឍនៃវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ឬករណីប្រធានសក្តិ ត្រូវអនុវត្តតាមគោលការណ៍ដូចមានចែងក្នុងមាត្រា១១នៃអនុក្រឹត្យនេះក្រោយពីទទួលបានការឯកភាពឬសេចក្តីសម្រេចឱ្យមានការកែប្រែឈ្មោះផ្លូវឬលេខផ្លូវពីរាជរដ្ឋាភិបាល។

ផ្នែកទី២
នីតិវិធីនៃការដាក់ឈ្មោះផ្លូវនិងការកែប្រែឈ្មោះផ្លូវ

មាត្រា ១៤.-

ឈ្មោះផ្លូវអាចដាក់ជាឈ្មោះវីរបុរស ឥស្សរជន សប្បុរសជន ឈ្មោះពីប្រវត្តិសាស្ត្រ ឈ្មោះតាមភូមិសាស្ត្រធម្មជាតិ ឈ្មោះតាមវប្បធម៌ ឈ្មោះពីបរមបុរាណ និងឈ្មោះតាមទម្លាប់។

មាត្រា ១៥.-

ការដាក់ឈ្មោះផ្លូវឬការកែប្រែឈ្មោះផ្លូវ ត្រូវធ្វើឡើងតាមសំណើរបស់គណៈកម្មាធិការសិក្សាស្រាវជ្រាវនិងរៀបចំបញ្ជីផ្លូវដែលបង្កើតឡើងតាមមាត្រា៦នៃអនុក្រឹត្យនេះ ទៅសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

មាត្រា ១៦.-

ក្នុងករណីមានបណ្តឹងតវ៉ាអំពីការដាក់ឈ្មោះផ្លូវឬការកែប្រែឈ្មោះផ្លូវ សាមីដើមបណ្តឹងត្រូវដាក់ពាក្យប្តឹងទៅគណៈកម្មាធិការសិក្សាស្រាវជ្រាវនិងរៀបចំបញ្ជីផ្លូវដែលជាសេនាធិការជូនសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ដើម្បីពិនិត្យនិងសម្រេច បន្ទាប់ពីមានការឯកភាពពីរាជរដ្ឋាភិបាល។

ផ្នែកទី៣
នីតិវិធីនៃការដាក់លេខផ្លូវ

មាត្រា ១៧.-

ការដាក់លេខផ្លូវនិងការកំណត់អត្តសញ្ញាណផ្លូវ ត្រូវកំណត់ដូចខាងក្រោម៖

- ចំណុចចាប់ផ្តើមនៃខ្នែងផ្លូវនីមួយៗ ត្រូវជ្រើសរើសក្នុងលក្ខណៈជាទីតាំងដែលមានសក្តានុពលខ្ពស់ផ្នែកសេដ្ឋកិច្ច សង្គម ឬមានប្រជាជនរស់នៅច្រើន ឬមានចរិតជាប្រវត្តិសាស្ត្រ ឬមានស្ពានស្ថិតនៅដើមផ្លូវនៃផ្លូវខ្នែង និងផ្លូវដែលផ្លូវខ្នែងបែកចេញមានអាទិភាពខ្ពស់ជាងផ្លូវដែលផ្លូវខ្នែងតភ្ជាប់
- ផ្លូវបែកចេញពីផ្លូវជាតិឬផ្លូវខេត្ត ត្រូវកំណត់យកលេខសេសសម្រាប់ខាងឆ្វេងដៃ និងលេខគូសម្រាប់ខាងស្តាំដៃ ដោយគិតពីផ្លូវដែលបែកចេញតាមទិសចេញពីរាជធានីភ្នំពេញ ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ
- តំបន់ភូមិសាស្ត្រផ្លូវថ្នល់ត្រូវបានបែងចែកសម្រាប់កំណត់ទីតាំងផ្លូវនិងដាក់លេខផ្លូវ
- ឈ្មោះរាជធានីនិងខេត្ត ត្រូវតាងដោយអក្សរកាត់សម្រាប់ផ្សំក្នុងការដាក់លេខផ្លូវ ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ។

មាត្រា ១៨.-

ការដាក់លេខផ្លូវត្រូវបានដាក់លេខតាមវិធីសាស្ត្រមួយដែលអាចកំណត់ច្បាស់នូវទីតាំងប្រភេទផ្លូវនិងអាទិភាពផ្លូវ។

ការដាក់លេខផ្លូវ ត្រូវចាប់ផ្តើមពីផ្លូវមានលេខមួយខ្ទង់ រហូតដល់ផ្លូវមានលេខបួនខ្ទង់។

ការដាក់លេខផ្លូវខេត្តនៅក្នុងខេត្ត ត្រូវគួបផ្សំលេខផ្លូវជាមួយអក្សរឡាតាំងដែលជាអក្សរកាត់សម្រាប់សម្គាល់ឈ្មោះខេត្តនោះ។

ឈ្មោះខេត្តជាខេមរភាសានិងជាអក្សរឡាតាំង ដែលសរសេរជាអក្សរកាត់ឡាតាំងសម្រាប់សម្គាល់ឈ្មោះខេត្ត ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះ។

មាត្រា ១៩.-

ផ្លូវជាតិកម្រិត១និងផ្លូវជាតិកម្រិត២ ត្រូវបានកំណត់ចំណុចចាប់ផ្តើមនៃទីតាំងមួយនិងចំណុចបញ្ចប់នៃទីតាំងមួយទៀត ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យនេះ។

ចំពោះផ្លូវខេត្តនិងផ្លូវជនបទ ការកំណត់ចំណុចចាប់ផ្តើមនៃទីតាំងមួយនិងចំណុចបញ្ចប់នៃទីតាំងមួយទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យផ្លូវថ្នល់។

ជំពូកទី៥
បទប្បញ្ញត្តិដោយឡែក

មាត្រា ២០.-

ឈ្មោះផ្លូវឬលេខផ្លូវដែលបានដាក់ឱ្យប្រើប្រាស់កន្លងមក ត្រូវរក្សាទុកដដែល លើកលែងតែមានការកែប្រែឈ្មោះផ្លូវឬលេខផ្លូវដែលធ្វើឡើងដោយរាជរដ្ឋាភិបាល។

រាជរដ្ឋាភិបាលមានសិទ្ធិដាក់ឈ្មោះផ្លូវថ្មីឬលេខផ្លូវថ្មីតាមការចាំបាច់។

មាត្រា ២១.-

ផែនទីនិងតារាងដែលភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ មិនមានឥទ្ធិពលផ្លូវច្បាប់ពីការកំណត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសជិតខាងឡើយ។

ជំពូកទី៦
អវសានប្បញ្ញត្តិ

មាត្រា ២២.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ២៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ : ផែនទីតំបន់ភូមិសាស្ត្រផ្លូវថ្នល់នៃអនុក្រឹត្យលេខ.....១០៩.....អនក្រ.បក ចុះថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ២០១៣ ស្តីពី បែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ(ផែនទីនិងតារាងដែលភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ មិនមានឥទ្ធិពលផ្លូវច្បាប់លើការកំណត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសជិតខាងឡើយ)

Annex1: Roads Regional Map of Sub-decree No. Dated 2013 on Formalities and Procedures of Naming Roads or Numbering Roads and Changing Naming Roads or Numbering Roads (the maps and tables in the attachment of this Sub-decree have no legal effect on the works of the demarcation, between the Kingdom of Cambodia and its Neighboring Countries)



ឧបសម្ព័ន្ធទី២ : លេខសេសសម្រាប់ខាងឆ្វេងដៃនិងលេខគូសម្រាប់ខាងស្តាំដៃ ដោយគិតពីផ្លូវដែលបែកចេញតាមទិសចេញពីរាជធានីភ្នំពេញនៃអនុក្រឹត្យលេខ...៣០៩... អនក្រ.បក ចុះថ្ងៃទី ១៨ ខែ ៣ ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ(ផែនទីនិងតារាងដែលភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ មិនមានឥទ្ធិពលផ្លូវច្បាប់លើការកំណត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសជិតខាងឡើយ)

Annex2 of Sub-decree No. Dated 2013 on Formalities and Procedures of Naming Roads or Numbering Roads and Changing Naming Roads or Numbering Roads (the maps and tables in the attachment of this Sub-decree have no legal effect on the works of the demarcation, between the Kingdom of Cambodia and its Neighboring Countries)



ឧបសម្ព័ន្ធទី៣ : ឈ្មោះរាជធានីនិងខេត្ត ត្រូវតាងដោយអក្សរកាត់សម្រាប់ផ្សំក្នុងការដាក់លេខផ្លូវនៃ អនុក្រឹត្យលេខ....១១៩....អនក្រ.បក ចុះថ្ងៃទី១៨ ខែ មិនា ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ(ផែនទីនិងតារាងដែលភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ មិនមានឥទ្ធិពលផ្លូវច្បាប់លើការកំណត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសជិតខាងឡើយ)

Annex3 of Sub-decree No. Dated 2013 on Formalities and Procedures of Naming Roads or Numbering Roads and Changing Naming Roads or Numbering Roads (the maps and tables in the attachment of this Sub-decree have no legal effect on the works of the demarcation, between the Kingdom of Cambodia and its Neighboring Countries)



ឧបសម្ព័ន្ធទី៤ : ឈ្មោះខេត្តជាខេមរភាសានិងជាអក្សរឡាតាំង ដែលសរសេរជាអក្សរកាត់ឡាតាំងសម្រាប់សម្គាល់ឈ្មោះខេត្តនៃអនុក្រឹត្យលេខ.១០៩........អនក្រ.បក ចុះថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ

១-	ខេត្តបន្ទាយមានជ័យ	Banteay Meanchey	អក្សរកាត់ឡាតាំង	BM
២-	ខេត្តបាត់ដំបង	Battambang	អក្សរកាត់ឡាតាំង	BB
៣-	ខេត្តកំពង់ចាម	Kampong Cham	អក្សរកាត់ឡាតាំង	KC
៤-	ខេត្តកំពង់ឆ្នាំង	Kampong Chhnang	អក្សរកាត់ឡាតាំង	KCh
៥-	ខេត្តកំពង់ស្ពឺ	Kampong Speu	អក្សរកាត់ឡាតាំង	KS
៦-	ខេត្តកំពង់ធំ	Kampong Thom	អក្សរកាត់ឡាតាំង	KT
៧-	ខេត្តកំពត	Kampot	អក្សរកាត់ឡាតាំង	KP
៨-	ខេត្តកណ្តាល	Kandal	អក្សរកាត់ឡាតាំង	KD
៩-	ខេត្តកោះកុង	Koh Kong	អក្សរកាត់ឡាតាំង	KK
១០-	ខេត្តក្រចេះ	Kratie	អក្សរកាត់ឡាតាំង	KRT
១១-	ខេត្តមណ្ឌលគិរី	Mondul Kiri	អក្សរកាត់ឡាតាំង	MK
១២-	រាជធានីភ្នំពេញ	Phnom Penh	អក្សរកាត់ឡាតាំង	PP
១៣-	ខេត្តព្រះវិហារ	Preah Vihear	អក្សរកាត់ឡាតាំង	PVH
១៤-	ខេត្តព្រៃវែង	Prey Veng	អក្សរកាត់ឡាតាំង	PV
១៥-	ខេត្តពោធិ៍សាត់	Pursat	អក្សរកាត់ឡាតាំង	PS
១៦-	ខេត្តរតនគិរី	Rattanak Kiri	អក្សរកាត់ឡាតាំង	RK
១៧-	ខេត្តសៀមរាប	Siem Reap	អក្សរកាត់ឡាតាំង	SR
១៨-	ខេត្តព្រះសីហនុ	Khet Preah Sihanouk	អក្សរកាត់ឡាតាំង	KPS
១៩-	ខេត្តស្ទឹងត្រែង	Stung Treng	អក្សរកាត់ឡាតាំង	ST
២០-	ខេត្តស្វាយរៀង	Svay Rieng	អក្សរកាត់ឡាតាំង	SVR
២១-	ខេត្តតាកែវ	Takeo	អក្សរកាត់ឡាតាំង	TK
២២-	ខេត្តឧត្តរមានជ័យ	Oddar Meanchey	អក្សរកាត់ឡាតាំង	ODM
២៣-	ខេត្តកែប	Kep	អក្សរកាត់ឡាតាំង	KEP
២៤-	ខេត្តប៉ៃលិន	Pailin	អក្សរកាត់ឡាតាំង	PL

ឧបសម្ព័ន្ធទី៥ : ផ្លូវជាតិកម្រិត១នៃអនុក្រឹត្យលេខ...១៨៩.......អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ៣ ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ(ផែនទីនិងតារាងដែលភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ មិនមានឥទ្ធិពលផ្លូវច្បាប់លើការកំណត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសជិតខាងឡើយ)

Annex5: 1-Digit National Road of Sub-decree No. Dated 2013 on Formalities and Procedures of Naming Roads or Numbering Roads and Changing Naming Roads or Numbering Roads (the maps and tables in the attachment of this Sub-decree have no legal effect on the works of the demarcation, between the Kingdom of Cambodia and its Neighboring Countries)

លេខផ្លូវ		ចំណុចផ្តើម	ចំណុចបញ្ចប់	ប្រវែងគិតជាគីឡូម៉ែត្រ
ចាស់	ថ្មី			
១	១	វត្តភ្នំ (ភ្នំពេញ)	បាវិត(ព្រំប្រទល់កម្ពុជា វៀតណាម)	១៦៦,៨៥០
២	២	គល់ស្ពានព្រះមុនីវង្ស (ផជ១-គ.ម ៥+០៧៥)	ភ្នំដិន(ព្រំប្រទល់កម្ពុជា វៀតណាម)	១២០,៦៩៥
៣	៣	វត្តភ្នំ (ភ្នំពេញ)	វាលរិញ(ផជ៤-គ.ម ១៨២+២៨០)	២០១,៥៨៩
៤	៤	ចោមចៅ (ផជ៣-គ.ម ១២+២០០)	ខេត្តព្រះសីហនុ	២១៤,២០០
៥	៥	វត្តភ្នំ (ភ្នំពេញ)	ប៉ោយប៉ែត(ព្រំប្រទល់កម្ពុជា ថៃ)	៤០៧,៤៥០
៦	៦	វត្តភ្នំ (ភ្នំពេញ)	សិរីសោភ័ណ(បន្ទាយមានជ័យ)	៤១៥,៤៧៧
៧	៧	ស្គន់ (ផជ៦-គ.ម ៧៥+០០០)	ត្រពាំងក្រៀល(ព្រំប្រទល់កម្ពុជា ឡាវ)	៤៦០,៨៣០
	៨	ព្រែកតាមាក់ (ផជ៦-គ.ម ២៤+៣៦០)	ក្រែក(ផជ៧-គ.ម ១៧៩+៥៣០)	១៣២,៣៥៦
២១៤	៩(*)	ភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង (ផជ៧-គ.ម ៤៥៨)	ភូមិស្លាពរ សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ(ផជ៦២-គ.ម១៣០)	១៤៣,៣២៦
ប្រវែងសរុបផ្លូវជាតិកម្រិត១ :				**២ ២៦២,៧៧៣**

បញ្ជាក់ : - ប្រវែងផ្លូវជាតិលេខ១ លេខ២ លេខ៣ លេខ៤ លេខ៥ និងលេខ៧ កំណត់យកតាមប្រវែងផ្លូវក្នុងប្រកាសលេខ[illegible] ខែតុលា ឆ្នាំ១៩៦៩។

- (*) អនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ[illegible] ក្នុងពិធីបើកការដ្ឋានសាងសង់ផ្លូវនិងស្ពានទន្លេមេគង្គនៅខេត្តស្ទឹងត្រែង នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១២។

ឧបសម្ព័ន្ធទី៥ : ផ្លូវជាតិកម្រិត២នៃអនុក្រឹត្យលេខ....១០៩.......អនក្រ.បក ចុះថ្ងៃទី ១៧ ខែ មិនា ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ(ផែនទីនិងតារាងដែលភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ មិនមានឥទ្ធិពលផ្លូវច្បាប់លើការកំណត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសជិតខាងឡើយ)

Annex5: 2-Digit National Road of Sub-decree No. Dated 2013 on Formalities and Procedures of Naming Roads or Numbering Roads and Changing Naming Roads or Numbering Roads (the maps and tables in the attachment of this Sub-decree have no legal effect on the works of the demarcation, between the Kingdom of Cambodia and its Neighboring Countries)

លេខផ្លូវ	ចំណុចផ្តើម	ចំណុចបញ្ចប់	ប្រវែងគិតជាគីឡូម៉ែត្រ
១១	អ្នកលឿង (ផជ១-គម ៦១+១៥០)	ថ្នល់ទទឹង (ផជ៧-គម ១៣៦+២៥៤)	៩០,២៥០
១៣	ស្វាយរៀង (ផជ១-គម ១២៦+៥០០)	ឃុំក្របៅ (ផជ៨-គម ១២៣+២៥៦)	៥៩,៥០០
២០	ក្រាំងស្វាយ (ផជ២)	កំពង់ទួល (ផជ៣)	៩,៦២៤
២១	តាខ្មៅ (ផជ២-គម ១១+០៩០)	ជ្រៃធំ (ព្រំប្រទល់កម្ពុជា វៀតណាម)	៦៥,៥៦២
២២	អូរចំបក់ (ផជ២-គម ៧៤+០១០)	អង្គតាសោម (ផជ៣-គម ៧៤+៨២០)	៩,៦១៥
២៣	ព្រែកហូរ (ផជ២)	ភូមិតាព្រហ្ម (ផជ១)	១២,៣៣០
៣១	បំបែកគូស (ផជ៣-គម ៨១+៩២០)	កំពង់ត្រាច (ផជ៣៣-គម១៨៣+៨១០)	៥៤,៨១០
៣២	កែបថ្មី (ផជ៣-គម ១៥៦+១០០)	ឧទ្យានជាតិបូកគោ	៣៣,៣២០
៣៣	កំពត (ផជ៣-គម ១៤៨+១០០)	ប្រកលក (ព្រំប្រទល់កម្ពុជា វៀតណាម)	៥២,២៧០
៤១	ថ្នល់ទទឹង	ល្បាង (ផងទង់)	៩៦,៤៥០
៤២	បែកចាន (ផជ៤-គម ១៤+០០០)	បាត់ដឹង (ផជ៥១-គម ១៦+៣០០)	២៤,២៦០

៤៣	ត្រែងត្រយឹង (ផជ៤-គម ៨៧+៨៧៧)	ទ្វារថ្មី (ផជ៣)	៧៨,៨៨០
៤៤	ច្បារមន (ផជ៤-គម ៤៩+០០០)	ឧត្តុង្គ (ផជ៥)	៨៤,៨៤០
៤៥	កងកេង (ផជ៤-គម ២០៩+១០០)	រាម	៩,៣០០
៤៦	ត្រែងត្រយឹង (ផជ៤-គម ៨៧+៨៧៧)	ឧទ្យានជាតិគីរីរម្យ	២៦,៩៥០
៤៨	ចំការលួង (ផជ៤-គម១៤២+៣៥០)	ចាំយាម (ព្រំប្រទល់កម្ពុជា ថៃ)	១៦១,២៧០
៥១	ឧត្តុង្គ (ផជ៥-គម ៣៨+៥៦០)	ថ្នល់ទទឹង	៣៨,០១០
៥២	ពន្លៃ (ផជ៥-គម១២៣+៦៤០)	ផ្អកទ្រូ	៨,០១០
៥៣	កំពង់ឆ្នាំង (ផជ៥-គ.ម៩១+០០០)	គោកពេញ	៦២
៥៣អា	ឃុំផ្សារ (ផជ៥)	ក្ដុល	២៩,២៨០
៥៣បេ	ក្រគរ (ផជ៥-គម ១៩៣)	កំរែង	២២,៣០០
៥៤	ក្រគរ (ផជ៥-គម ១៩៣)	កំពង់លួង (ទន្លេសាប)	៤,៨៧០
៥៥	ទីរួមខេត្តពោធិ៍សាត់ (ផជ៥- គ.ម ១៨៤+៨៥០)	ថ្មដា (ព្រំប្រទល់កម្ពុជា ថៃ)	១៨៥,២០០
៥៦	បន្ទាយមានជ័យ (ផជ៥-គ.ម ៣៥៩+៧៨០)	ឧត្តរមានជ័យ	១១៣,៦២០
៥៧	បាត់ដំបង (ផជ៥- គ.ម ២៩១+០១០)	ព្រំ (ព្រំប្រទល់កម្ពុជា ថៃ)	១០៣,៣៤០
៥៧បេ	ថ្មគោល (ផជ៥-គ.ម ៣៣១+២៤០)	សំពៅលូន	៩០,២០០
៥៧បេ-១	បវេល ភូមិសាមសិប	ភ្នំព្រឹក	៦៩,៧៥០
៥៧បេ-២	ភូមិសាមសិប កំរៀង	អូរដា	១៦,៤០០

៥៨	អូរជ្រៅ (ផជ៥- គ.ម ៤០៥+៩៩០)	ថ្មដូន	២៥០,២០០
៥៩	កូនដំរី (ផជ៥-គ.ម ៣៩២+៨២០)	សំពៅលូន — រថក្រោះឆេះ (ផជ៥៧)	១៤០,២៥០
៦០	សំពងជ័យ (ផជ៦-គ.ម ៩១+៤៣០)	ព្រៃទទឹង (ផជ៧-គ.ម ៩៥១+១២០)	១៩,៩៤០
៦១	ថ្នល់កែង (ផជ៦-គ.ម ៤៦+៩៥០)	ព្រែកក្ដាម (ផជ៥)	១៥,៨៥០
៦២	ថ្នល់បែក (ផជ៦-គ.ម ១៧០+៩៥០)	ប្រាសាទព្រះវិហារ	២៤២,៦៦០
៦៣	សៀមរាប(ផជ៦- គ.ម ៣១១+៧២០)	ចុងឃ្នាស (ភ្នំក្រោម)	១៤,៣១០
៦៤	ដំដែក (ផជ៦)	ថ្នល់បែក (ផជ៦២)	១១២,១៦០
៦៧	ស្វាយធំ (ផជ៦)	ជាំ (ព្រំប្រទល់កម្ពុជា ថៃ)	១៣៣,៨៧០
៦៨	ក្រឡាញ់ (ផជ៦-គ.ម ៣៦៥+៩២៦)	អូរស្មាច់ (ព្រំប្រទល់កម្ពុជា ថៃ)	១១៦,៨៦០
៧០	ព្រៃទទឹង (ផជ៧-គ.ម ៩៥+២២០)	ពាមជីកង (កំពង់ចាម)	១៣,៥៣០
៧១	ត្រើង (ផជ៧-គ.ម ១០៥+៨២២)	កំពង់ថ្ម (ផជ៦- គ.ម ១២៨+២៤០)	៥៧,៨៣០
៧២	ក្រែក (ផជ៧-គ.ម ១៧៥+៥៣០)	ត្រពាំងផ្លុង(ព្រំប្រទល់កម្ពុជា វៀតណាម)	១៣,៥០០
៧៣	ប្រធាតុ (ផជ៧-គ.ម ១៦០+០០០)	ក្រចេះ	៩២,៤០០
៧៤	ស្នួល (ផជ៧-គ.ម ២៥៤+៩៣០)	ត្រពាំងស្រែ(ព្រំប្រទល់កម្ពុជា វៀតណាម)	២១,១២០
៧៦	ស្នួល (ផជ៧-គ.ម ២៥៤+៩៣០)	តាអង្គ (ផជ៧៨-គ.ម ៥៧៥+០០០)	៣០៦,១៨០
៧៨	អូរពងមាន់ (ផជ៧-គ.ម ៤៥៩+៧០០)	អូរយ៉ាដាវ (ព្រំប្រទល់កម្ពុជា វៀតណាម)	១៩១,៧០០
៨៨	ក្រពៅ (ផជ៨)	ម៉ឺនជ័យ	៥,៦៣០
ប្រវែងសរុបផ្លូវជាតិកម្រិត២ :			**៣ ៣៦០,៣១១**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១៧ . អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការដំឡើងស្ថានីយ៍ផលិតគ្រាប់ពូជទី១ ទៅជា វិទ្យាស្ថានជាតិស្រាវជ្រាវ និងអភិវឌ្ឍន៍ធារីវប្បកម្មសម្តេចតេជោ ហ៊ុន សែន

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ /នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សម្រេច

មាត្រា ១.-

ត្រូវបានដំឡើងស្ថានីយ៍ផលិតត្រីពូជទី១ ទៅជាវិទ្យាស្ថានជាតិស្រាវជ្រាវ និងអភិវឌ្ឍវារីវប្បកម្ម សម្តេចតេជោ ហ៊ុន សែន ដែលសរសេរជាអក្សរកាត់ថា វ.ជ.ហ.ស. មានថ្នាក់ស្មើនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

វ.ជ.ហ.ស.មានទីតាំងស្ថិតនៅ ភូមិព្រែកឡុង ឃុំការខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ។

មាត្រា ២.-

វ.ជ.ហ.ស. មានតួនាទី និងភារកិច្ច ដូចតទៅ ៖

- សិក្សាស្រាវជ្រាវលក្ខណៈជីវសាស្ត្រ និងជ្រើសរើសពូជវារិជាត
- សិក្សាស្រាវជ្រាវបច្ចេកទេសថែបំប៉នមេពូជ ផលិត បង្កាត់ពូជវារិជាត
- សិក្សាស្រាវជ្រាវបច្ចេកទេសប្រើប្រាស់ថ្នាំ និងអរម៉ូនសម្រាប់វារិជាត
- សិក្សាស្រាវជ្រាវបច្ចេកទេសចិញ្ចឹមប្រភេទវារិជាត ដែលមានតម្លៃសេដ្ឋកិច្ច
- សិក្សាស្រាវជ្រាវបច្ចេកទេសផលិតប្រភេទវារិជាតមានដោយកម្រ ដែលជិតផុតពូជ
- សិក្សាស្រាវជ្រាវបច្ចេកទេសថែរក្សា ផលិតចំណីធម្មជាតិ និងចំណីសិប្បនិម្មិត
- សិក្សាស្រាវជ្រាវ និងបង្កើនសមត្ថភាពមន្ទីរពិសោធន៍ ផ្នែកវិភាគគុណភាពទឹក ចំណី ជំងឺវារិជាត និងវិធីសាស្ត្រព្យាបាល
- សិក្សាស្រាវជ្រាវនិងអភិរក្សសេនេទិកវារិជាត
- បណ្តុះបណ្តាល និងបំពាក់បំប៉នបច្ចេកវិទ្យាវារីវប្បកម្ម
- បង្កើតមូលដ្ឋានទិន្នន័យ ចងក្រងឯកសារ និងផ្សព្វផ្សាយព័ត៌មានបច្ចេកទេសវារីវប្បកម្ម
- ធ្វើសហប្រតិបត្តិការជាមួយអង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័ននានាក្នុងកិច្ចសហការស្រាវជ្រាវវារីវប្បកម្ម
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំរដ្ឋបាលជលផល ប្រគល់ឱ្យ ។

វ.ជ.ហ.ស.ដឹកនាំដោយ នាយកមួយរូប មានថ្នាក់ស្មើប្រធាននាយកដ្ឋាន និងអមដោយនាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

មាត្រា ៣.-

ការរៀបចំនិងការប្រព្រឹត្តទៅរបស់វ.ជ.ហ.ស. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២០ខែ មីនា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :១២៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៦អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន១៩ ២៥៨ ៤០០ ០០០រៀល(ដប់ប្រាំបួនពាន់ពីររយហាសិបប្រាំបីលានបួនរយពាន់រៀលគត់) ពីជំពូក០៩(ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក៦០(ការទិញ) ជូនក្រសួងមហាផ្ទៃ(សន្តិសុខសាធារណៈ) សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់ដំណាក់កាលទី១ លើកទី១ ថ្លៃទិញឧបករណ៍សម្ភារៈបច្ចេកទេសសម្រាប់ផលិតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជំហាន២ ជូនក្រុមហ៊ុន អេច អេស ស៊ី ខូ អិលធីឌី។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ៣ ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :..១៧៣...អនក្រ-បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៦អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

មាត្រា១:ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន៧ ១៦៧ ១០០ ០០០រៀល(ប្រាំពីរពាន់មួយរយហុកសិបប្រាំពីរលានមួយរយពាន់រៀលគត់) ពីជំពូក០៩(ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក៦៥ (ឧបត្ថម្ភកធននិងជំនួយសង្គម) ជូនទីស្តីការគណៈរដ្ឋមន្ត្រីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។

មាត្រា២:ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់ចំណាយរៀបចំព្រះរាជពិធីបុណ្យព្រះបរមសព **ព្រះករុណា ព្រះបរមរតនកោដ្ឋ** (ជំហានទី៤)។

មាត្រា៣:រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ៣ ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៩១៦ - អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ .បក ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និង សាសនា
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សម្រេច

មាត្រា ១ : ត្រូវបានដាក់មន្ត្រីរាជការឋានន្តរសក្តិរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ស្ថាប័ន ចំនួន ១២ រូប ឱ្យចូលនិវត្តន៍ ដូចមានរាយនាមខាងក្រោម ៖

ល.រ	គោត្តនាម និង នាម	ភេទ	ថ្ងៃខែឆ្នាំកំណើត	មុខតំណែង	ឋានន្តរសក្តិ និង ថ្នាក់	ថ្ងៃខែឆ្នាំ ចូលនិវត្តន៍
ក្រសួងធម្មការ និងសាសនា						
១	**សេង ណារត**	ប	០២-០២-១៩៥៣	អគ្គនាយករង	រមន្ត្រី ថ្នាក់លេខ ៥	០១-០៣-២០១៣
២	**ឃិន ចំរើន**	ស	០៣-០៩-១៩៥៣	ប្រធាននាយកដ្ឋាន	រមន្ត្រី ថ្នាក់លេខ ៦	០១-១០-២០១៣
៣	**ស្រី ស៊ីលីម**	ស	២៧-០៧-១៩៥៣	ប្រធាននាយកដ្ឋាន	រមន្ត្រី ថ្នាក់លេខ ៧	០១-០៨-២០១៣

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់						
១	**កែវ កុសល**	ប	១៥-០៥-១៩៥២	អគ្គនាយករង	វរមន្ត្រី ថ្នាក់លេខ ៣	០១-០៦-២០១២
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ						
១	**ញិម ច័ន្ទថេត**	ប	០៧-០៦-១៩៥២	ប្រធាននាយកដ្ឋាន	វរមន្ត្រី ថ្នាក់លេខ ៤	០១-០៧-២០១២
ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍						
១	**លីម លឿង**	ស	១២-០៧-១៩៥៣	ប្រធាននាយកដ្ឋាន	វរមន្ត្រី ថ្នាក់លេខ ៨	០១-០៨-២០១៣
ក្រសួងពាណិជ្ជកម្ម						
១	**រាម តាង**	ប	០២-០៥-១៩៥៣	អគ្គាធិការរង	វរមន្ត្រី ថ្នាក់លេខ ៦	០១-០៦-២០១៣
២	**អ៊ុយ សុខារាត្ត**	ប	០១-០១-១៩៥៣	អគ្គនាយករង	វរមន្ត្រី ថ្នាក់លេខ ២	០១-០២-២០១៣
៣	**ខង្ស ច័ន្ទតារា**	ប	២០-១០-១៩៥៣	អគ្គនាយករង	វរមន្ត្រី ថ្នាក់លេខ ៦	០១-១១-២០១៣
៤	**ហេង សុខុម**	ប	០៦-០៣-១៩៥៣	អគ្គនាយករង	វរមន្ត្រី ថ្នាក់លេខ ៦	០១-០៤-២០១៣
៥	**ភាំង សុជាតិ**	ប	១១-០៥-១៩៥៣	ប្រធាននាយកដ្ឋាន	វរមន្ត្រី ថ្នាក់លេខ ៦	០១-០៦-២០១៣
ក្រសួងសុខាភិបាល						
១	**ជា ម៉ុនហេង**	ប	១៤-០៣-១៩៥៣	អគ្គាធិការរង	វរមន្ត្រី ថ្នាក់លេខ ៣	០១-០៤-២០១៣

មាត្រា ២ : ត្រូវបានដាក់មន្ត្រីរាជការឋានន្តរសក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ របស់ក្រសួង ស្ថាប័ន ចំនួន ០២ រូប ឱ្យចូលនិវត្តន៍ ដូចមានរាយនាមខាងក្រោម ៖

ល.រ	គោត្តនាម និង នាម	ភេទ	ថ្ងៃខែឆ្នាំកំណើត	មុខតំណែង	ឋានន្តរសក្តិ និង ថ្នាក់	ថ្ងៃខែឆ្នាំ ចូលនិវត្តន៍
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់						
១	**យស នោមណារ៉ាឌី**	ប	០៣-០២-១៩៥២	អនុប្រធានមន្ទីរ	មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩	០១-០៣-២០១២
ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍						
១	**ឡៅ សារឿន**	ប	០១-០៣-១៩៥៣	ប្រធាននាយកដ្ឋាន	មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨	០១-០៤-២០១៣

មាត្រា ៣ : ត្រូវបានដាក់មន្ត្រីរាជការឋានន្តរសក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់របស់ក្រសួងសុខាភិបាល ចំនួន ០៨ រូប ឱ្យចូលនិវត្តន៍ ដូចមាននាមខាងក្រោម ៖

ល.រ	គោត្តនាម និង នាម	ភេទ	ថ្ងៃខែឆ្នាំកំណើត	មុខតំណែង	ឋានន្តរសក្តិ និង ថ្នាក់	ថ្ងៃខែឆ្នាំ ចូលនិវត្តន៍
១	**ហ៊ី សុប្រាភា**	ស	២៩-០៤-១៩៥៣	សាស្ត្រាចារ្យ មហាបរិញ្ញា	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩	០១-០៥-២០១៣
២	**អ៊ុំ សុខុម**	ប	១៥-០៤-១៩៥៣	សាស្ត្រាចារ្យ មហាបរិញ្ញា	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩	០១-០៥-២០១៣
៣	**អ៊ុង សុផ្លាទី**	ស	៣០-១២-១៩៥៣	ឱសថបណ្ឌិត	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩	០១-០១-២០១៤
៤	**ជួន ចន្ថោភាស**	ស	០១-០១-១៩៥៣	ឱសថបណ្ឌិត	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩	០១-០២-២០១៣

៥	**យឹត ស៊ុនណារ៉ុខ**	ប	០៣-០៧-១៩៥៣	សាស្ត្រាចារ្យ មហាបរិញ្ញា	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩	០១-០៨-២០១៣
៦	**តាន់ សុខៈ**	ស	០៦-០៥-១៩៥៣	សាស្ត្រាចារ្យ មហាបរិញ្ញា	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩	០១-០៦-២០១៣
៧	**គាំខ ស៊**	ប	១៣-០៨-១៩៥៣	សាស្ត្រាចារ្យ មហាបរិញ្ញា	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩	០១-០៩-២០១៣
៨	**ថាន់ ថាណាសិទ្ធិ**	ប	០៩-០៨-១៩៥៣	គ្រូពេទ្យការពារ	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩	០១-០៩-២០១៣

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមាន ចែងក្នុងមាត្រា ១ មាត្រា ២ និងមាត្រា ៣ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ៨ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ [illegible]

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១: តែងតាំងលោកស្រី **ឆាយ គីម សុខ្ខាវី** ជាប្រធាននាយកដ្ឋានសុខភាពសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា ជំនួសលោក **ម៉ែន សារឿន** ដែលត្រូវដាក់ឲ្យចូលនិវត្តន៍ នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៣ ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៩១៨.អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដំឡើងឋានន្តរសក្តិ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : ត្រូវបានដំឡើងឋានន្តរសក្តិថ្នាក់ វរសេនីយ៍ឯក នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

១-វរសេនីយ៍ទោ **ម៉ែន សុក្រឹត្យវិឡា** អត្តលេខ ០២៣៩៨៦ នាយករងទីចាត់ការហិរញ្ញ អគ្គបញ្ជាការដ្ឋាន

២-វរសេនីយ៍ទោ **ឡោ សំអួន** អត្តលេខ ០១៨៨២១ នាយក សាលាពលទាហានទី២ យោធភូមិភាគទី២

៣-វរសេនីយ៍ទោ **សួន សុន** អត្តលេខ ០០៥០០៨ នាយក សាលាពលទាហានទី៥ យោធភូមិភាគទី៥

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិង បណ្តាសមាសភាព ដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ៨ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៩៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមុខងារ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : ត្រូវបានតែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូន ឧត្តមសេនីយ៍ឯក **យឿង សុខុន** អត្តលេខ ០០០១២៣ ជាមេបញ្ជាការរង កងទ័ពជើងគោក និងជាមេបញ្ជាការ យោធភូមិភាគទី៣ ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ៨ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៩២០ . អនក្រ . បក

អនុក្រឹត្យ
ស្តីពី
ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ១២៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ ស្តីពីការបង្កើតសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា១.-

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ដូចមានរាយនាមខាងក្រោម ៖

១- ឯកឧត្តម **ម៉ម ប៊ុនហេង** តំណាងក្រសួងសុខាភិបាល ប្រធាន

២- ឯកឧត្តម **ម៉ុន សុខ** តំណាងក្រសួងអប់រំ យុវជន និងកីឡា សមាជិក

៣- ឯកឧត្តម **ហោខ តៃត្រី** ឥស្សរជនមានចំណេះដឹងនិងបទពិសោធន៍ខាងវិទ្យាសាស្ត្រសុខាភិបាល សមាជិក

៤- ឯកឧត្តម **ស៊ុំ ម៉ាប់** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៥- ឯកឧត្តម **ទូច ឡេខ** តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៦-ឯកឧត្តម **សាផុន វឌ្ឍនៈ** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល សមាជិកស្វ័យប្រវត្តិ

៧- លោកស្រីសាស្ត្រាចារ្យ **អ៊ុក សាវ៉ៃ** តំណាងបុគ្គលិកសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល សមាជិកស្វ័យប្រវត្តិ។

មាត្រា២.-

អនុក្រឹត្យលេខ៥៣៥ អនក្រ.តត ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ៨ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា៣

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៩២១.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនប្រធានអង្គការ និងទីប្រឹក្សាអង្គការ ចំនួន ០៧រូប ដែលមានស្នាដៃល្អក្នុងការអនុវត្តគម្រោងកម្មវិធី លើវិស័យពិការភាព នៅព្រះរាជាណាចក្រកម្ពុជា សម្រេចបាន លទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

១-	Ms. Seng SOLADY	មន្ត្រីកម្មវិធី JICA ប្រចាំប្រទេសកម្ពុជា
២-	Father. ChaslesDittmeier	ទីប្រឹក្សាគម្រោងគ-ផ្តល់ អង្គការម៉ារីណុល
៣-	Mr. Katano Tomoyuki	ប្រធានអ្នកស្ម័គ្រចិត្តជប៉ុនសម្រាប់ការផ្តល់រទេះជនពិការក្រៅប្រទេស
៤-	Ms. Pauline Kleinitz	មន្ត្រីទទួលបន្ទុកផ្នែកសុខភាព និងស្តារលទ្ធភាពពលកម្មអង្គការ WHO
៥-	Mr. Rodney Mearns	ប្រធានក្រុមប្រឹក្សាភិបាល LMDS
៦-	Ms. Hannah Stevens	គ្រប់គ្រងទូទៅអង្គការ EPIC ARTS
៧-	Ms. JoanaThomson	ប្រធានកម្មវិធីអង្គការ RCRC

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ៨ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៩២៧ អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយសហមេត្រី តាមលំដាប់ថ្នាក់ ជូនថ្នាក់ដឹកនាំអង្គការ និងទីប្រឹក្សា ចំនួន ១៩រូប ដែលមានស្នាដៃល្អ ក្នុងការអនុវត្តគម្រោងកម្មវិធី លើវិស័យពិការភាព នៅព្រះរាជាណាចក្រកម្ពុជា សម្រេចបាន លទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

ក-មេដាយសហមេត្រី ថ្នាក់ សេនា

១- Mr. Michael Wilson ប្រធានទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលីប្រចាំតំបន់មេគង្គ
២- Sr. Denise Coghlan អតីតនាយិកាប្រចាំប្រទេសកម្ពុជា អង្គការ JSC
៣- Mr. HaraldSchmid De Gruneck ប្រធានបេសកកម្មប្រចាំប្រទេសកម្ពុជាអង្គការ CIOMAL
៤- Mr. James Gollogly នាយកប្រចាំប្រទេសអង្គការ CSC
៥- Mr. Christopher Minko អគ្គលេខាធិការអង្គការសម្ព័ន្ធកីឡាបាល់ទះជនពិការជាតិកម្ពុជា
៦- Mr. Michael Scott ប្រធានអង្គការ CT ប្រចាំប្រទេសកម្ពុជា
៧- Father Jonh Barth អតីតនាយកគម្រោងស្តារពលកម្មជនពិការផ្នែកអង្គការម៉ារីណុល

ខ-មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ

១- Mr. Binjamin NGUYEN នាយកកម្មវិធីប្រចាំតំបន់កម្ពុជា ថៃ នៃអង្គការជនពិការអន្តរជាតិបារាំង
២- Mr. Jeroenstol នាយកប្រចាំប្រទេស អង្គការជនពិការ បែលហ្ស៊ិក
៣- Ms. Silvana Mehra ប្រធានការិយាល័យប្រចាំតំបន់មជ្ឈិមអាស៊ីបូព៌ា CBM
៤- Ms. Edwina Falthful-Farmer ប្រធានកម្មវិធីអន្តរជាតិរបស់អង្គការ CBM Australia
៥- Mr. Santiago DE COL ប្រធានសម្របសម្រួលប្រចាំប្រទេស នៃអង្គការ New Humanity
៦- Mr. Herve Roqueplan អតីតនាយកអង្គការ NH

៧-	Mr. Claude Tardif	ប្រធានគម្រោងកម្មវិធីស្តារលទ្ធភាពពលកម្មកាយសម្បទាអង្គការ ICRC ប្រចាំនៅហ្សឺណែវ
៨-	Mr. Peter Eichenberger	ប្រធានមូលនិធិ Mine-Ex Foundation (ហ្សឺណែវ)
៩-	Mr. YannDrouet	ប្រធានកម្មវិធីស្តារលទ្ធភាពពលកម្មកាយសម្បទាអង្គការ ICRC
១០-	Ms. Marion Fromm	ប្រធានអង្គការ RTC
១១-	Mr. David Curtis	អ្នកសម្របសម្រួលកម្មវិធីអង្គការ ARC
១២-	Brother Terry Heinrich	ប្រធានក្រុមប្រឹក្សា MSC

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ... ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា

សម្រេច

មាត្រា ១.-

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៩៨៣ សម្រេច-ឯស

អនុក្រឹត្យ
ស្តីពី
ការដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ វរសេនីយ៍ឯក ជាកិច្ចបច្ឆាមរណៈ ជូនសព

- វរសេនីយ៍ទោ **ឡា តារា** អត្តលេខ ០០៩១៩៥ នាយរងការិយាល័យបុគ្គលិក បញ្ជាការដ្ឋានកងទ័ពជើងអាកាស

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ.ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៩៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមុខតំណែងនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ត្រី **ឡាយ ម៉ុនថន** អត្តលេខ ០៣៦៩៥ ជំនួយការឯកឧត្តម ឡាយ សុខា អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទៅជាអនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១៨ ខែ ៨ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

[illegible signature and stamp]

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៩៤៥.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៩៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការប្រែក្លាយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា១.-

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដូចមានរាយនាមខាងក្រោមៈ

១- ឯកឧត្តម **ស៊ា ហួច** តំណាងក្រសួងសុខាភិបាល ប្រធាន

២- ឯកឧត្តម **សឹង រេត** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៣- លោកជំទាវ **ម៉ែន វិភាស៊ី** ឥស្សរជនមានចំណេះដឹងនិងបទពិសោធន៍ខាងវិទ្យាសាស្ត្រសុខាភិបាល សមាជិក

៤- លោក **អេង ទួច** តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៥- លោក **ឡុង ឌីម៉ង់** តំណាងសាលារាជធានីភ្នំពេញ សមាជិក

៦- លោកសាស្ត្រាចារ្យ **ឌី ម៉េង** នាយកមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត សមាជិកស្វ័យប្រវត្តិ

៧- លោកសាស្ត្រាចារ្យ **ឌឹង យ៉ៅយ៉េន** តំណាងបុគ្គលិកមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត សមាជិកស្វ័យប្រវត្តិ។

មាត្រា២.-

អនុក្រឹត្យលេខ១៤៩៦ អនក្រ.តត ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៩៥៦.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការ **អេហ្វ អេច អាយ** ៣៦០ (FHI 360) ដែលមានស្នាដៃល្អក្នុងការចូលរួមជួយឧបត្ថម្ភថវិកា សំភារៈ និងបច្ចេកទេស ដល់វិស័យសុខភាព និងអប់រំ កន្លងមក ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៩៤៧.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ ជូនសប្បុរសជន ចំនួន១៥រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយឧបត្ថម្ភថវិកា សំភារៈ និងបច្ចេកទេស ដល់វិស័យសុខភាព និងអប់រំ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-លោកស្រី	ផាំ	ហ្វាយយ៉ាង	សមាជិកគណៈកម្មាធិការប្រតិបត្តិនិងជាអតីតប្រធាននា.ទំនាក់ទំនងអន្តរជាតិនៃសហព័ន្ធនារីវៀតណាម
២-លោកស្រី	ត្រាន់	ធីហ័រ	អតីតប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃសហព័ន្ធនារីវៀតណាម
៣-លោកស្រី	ត្រាន់	ហ្វុងវិន	នាយករងនៃសាខាសាលាបណ្តុះបណ្តាលស្ត្រី សហព័ន្ធនារីវៀតណាម
៤-លោកស្រី	ប៊ួយ	ធីមីដួង	គ្រូបណ្តុះបណ្តាលនៃសាខាសាលាបណ្តុះបណ្តាលស្ត្រី សហព័ន្ធនារីវៀតណាម
៥-លោកស្រី	ង្វៀន	ធីញ៉ីធួយ	អនុប្រធានមន្ទីរមហាផ្ទៃ ទីក្រុងហូជីមិញ
៦-លោកស្រី	ង្វៀន	ធីធូហា	អនុប្រធានសហព័ន្ធនារីវៀតណាម
៧-លោក	ស្ទីវ	ផេនហ៊្វល	នាយកអង្គការ អេហ្វ អេច អាយ៣៦០
៨-លោកស្រី	អាមី	ថេសម៉េន	នាយកផ្នែកកម្មវិធីបង្ការ អង្គការ អេហ្វ អេច អាយ៣៦០
៩-លោក	ចៀប	ស្រ៊ុន	នាយកផ្នែកហិរញ្ញវត្ថុនិងលទ្ធកម្ម អង្គការ អេហ្វ អេច អាយ៣៦០
១០-លោក	ស៊ា	សុឃន់	នាយកផ្នែកការទំនាក់ទំនងជាយុទ្ធសាស្ត្រ ដើម្បីផ្លាស់ប្តូរការប្រព្រឹត្ត
១១-លោក	តាន់	សុខុន	អ្នកសំរបសំរួលកម្មវិធីបង្ការ អង្គការ អេហ្វ អេច អាយ៣៦០
១២-លោកស្រី	មូត	សុគុន្ធី	មន្ត្រីបច្ចេកទេសជាន់ខ្ពស់កម្មវិធីស្មាតហ្គើលនិងអតិថិជន អង្គការ អេហ្វ អេច អាយ៣៦០
១៣-លោកស្រី	នឹត	សុផា	មន្ត្រីបច្ចេកទេសជាន់ខ្ពស់ផ្នែកបង្ការការប្រើប្រាស់គ្រឿងញៀន អង្គការ អេហ្វ អេច អាយ៣៦០
១៤-លោក	ម៉ៅ	ឡុន	មន្ត្រីបច្ចេកទេសជាន់ខ្ពស់ អង្គការ អេហ្វ អេច អាយ៣៦០
១៥-លោកស្រី	សេង	សុភាព	មន្ត្រីបច្ចេកទេសជាន់ខ្ពស់ អង្គការ អេហ្វ អេច អាយ៣៦០

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ៨ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៩៤៨.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមាសការងារ ជូនសិល្បករ និងសិល្បការិនី ចំនួន១៤រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមសំដែងសិល្បៈដោយស្ម័គ្រចិត្ត ក្នុងឱកាសប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-លោក	អាន	សំអុល	តារាចម្រៀង
២-លោក	ប៊ុន	សុណារិន	តារាចម្រៀង
៣-កញ្ញា	ឃីន	ស្រីនាថ	តារាចម្រៀង
៤-លោក	ហេង	សុវណ្ណតារា	តារាចម្រៀង
៥-លោក	ចែម	ចាន់រ៉ា	តារាកំប្លែង
៦-លោក	ចែម	សារឿន	តារាកំប្លែង
៧-លោក	សេន	សុបុន	តារាកំប្លែង
៨-លោក	ប៉ុល	សារឿង	តារាកំប្លែង
៩-លោក	អ៊ឹម	ធូរ៉ែន	តារាកំប្លែង
១០-អ្នកនាង	ស្រេង	សុភាន់ដា	តារាកំប្លែង
១១-អ្នកនាង	សេន	ចិន្តា	តារាកំប្លែង
១២-អ្នកស្រី	ពៅ	ចាន់ធូ	តារាកំប្លែង
១៣-អ្នកនាង	លាប	សោភ័ណ្ឌ	តារាកំប្លែង
១៤-លោក	សេង	ចាន់ណា	តារាកំប្លែង

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៩៤៩ . អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ ជូនសិល្បករ និងសិល្បការិនី ចំនួន០៩រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមសំដែងសិល្បៈដោយស្ម័គ្រចិត្ត ក្នុងឱកាសប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-លោក	សុវណ្ណ ឫទ្ធី	ប្រធានដឹកនាំការសម្តែងក្រុមកំប្លែង CTN
២-លោក	ម៉ែន និមលរតន៍	ប្រធានគ្រប់គ្រងក្រុមបង្ហាញម៉ូតសាន់ម៉ូដែល
៣-លោក	ហួត ស៊ីថន	ប្រធានដឹកនាំការសម្តែងក្រុមកំប្លែងសាលាវិចិត្រសិល្បៈ
៤-លោកស្រី	ម៉េម ស៊ីណារ៉េត	ប្រធានក្រុមរបាំបុរាណសាលាវិចិត្រសិល្បៈ
៥-លោក	ណយ វណ្ណណេត	តារាចម្រៀង
៦-អ្នកនាង	ម៉េង កែវពេជ្ជតា	តារាចម្រៀង
៧-អ្នកនាង	ហ៊ឹម ស៊ីវន	តារាចម្រៀង
៨-កញ្ញា	ញឹម ចាន់ថន	តារាចម្រៀង
៩-លោក	ទេពរិទ្ធ ដារ៉ូ	តារាភាពយន្ត

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៨៥០ . អនក្រ . បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ** ចំនួន ០១គ្រឿង ជូនលោក **សេង សុវណ្ណ** ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តព្រះសីហនុ ដែលមានស្នាដៃល្អ ក្នុងការសាងសង់មជ្ឈមណ្ឌលភូមិកុមារអរុណរះទី៣ លើផ្ទៃដី ៥ហិកតា នៅភូមិស្នាច់ដែង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានអាគារ ២១ ខ្នង និងសម្ភារៈផ្សេងៗ ជាច្រើនទៀត។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៩៥១ .អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ចំនួន ០២គ្រឿង ជូនមន្ត្រីអង្គការ ដែលមានស្នាដៃល្អ ក្នុងការសាងសង់មជ្ឈមណ្ឌលភូមិកុមារអរុណរះទី៣ លើផ្ទៃដី ៥ហិកតា នៅភូមិស្នាច់ដែង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដូចមានរាយនាមខាងក្រោម៖

១-លោក **ឃី សុខសាន្ត** ប្រធានប្រតិបត្តិប្រចាំកម្ពុជា នៃមូលនិធិអូស្ត្រាលី-កម្ពុជា
២-លោក **សុខ ផល្លា** នាយកប្រតិបត្តិអង្គការក្តីសង្ឃឹមនៃកុមារកម្ពុជា

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ៨ ឆ្នាំ ២០១២
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧ សសរ

សេចក្ដីសម្រេច

ស្ដីពីនិរាករណ៍សេចក្ដីជូនដំណឹងរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី

លេខ ៦៦៩ ស.ជ.ណ ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

សម្រេច

ប្រការ ១ : និរាករណ៍សេចក្ដីជូនដំណឹង លេខ ៦៦៩ ស.ជ.ណ ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១ របស់ទីស្ដីការគណៈរដ្ឋមន្ត្រីស្ដីពីករណីទំនាស់ដីធ្លីនៅភូមិកែវផុស ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង បច្ចុប្បន្ននៅភូមិកែវផុស ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ រវាងលោក ជៀម ផែន ជាមួយនឹងប្រជាពលរដ្ឋចំនួន ៤៩ គ្រួសារ ។

ប្រការ ២ : ប្រគល់ភារកិច្ចជូនឯកឧត្ដមឧបនាយករដ្ឋមន្ត្រី **ប៊ិន ឈិន** ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដឹកនាំក្រុមការងារចុះពិនិត្យដោះស្រាយនៅហ្នឹងកន្លែង ។

ប្រការ ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តសេចក្ដីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ ២០១៣

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០០៩ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ ២០១២

ប្រកាសរួម

ស្ដីពី

ការផ្ដល់សេវាសាធារណៈរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការងារ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- តាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ស ម្រេ ច

ប្រការ ១ :

អនុញ្ញាតឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

កម្រងសេវាសាធារណៈនេះ មានបញ្ជាក់លម្អិតអំពីតម្លៃសេវា រយៈពេលផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងប្រកាសរួមនេះ។

ប្រការ ២ :

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវា ក្នុងនោះរួមមាន ៖ តារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវា ពាក់ព័ន្ធនឹងការប្រមូលចំណូលខាងលើនេះ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងដោយហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវ ជាដើម។

ប្រការ ៣ :

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូលបាន និងបង់ប្រាក់ចំណូលចូលថវិកាជាតិ ក្នុងនោះ ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ ស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាថវិកា ព្រមទាំងធ្វើសលាកប័ត្រចំណូល។

ប្រការ ៤ :

ការបែងចែកភារកិច្ចលើការគ្រប់គ្រង ការប្រមូលចំណូល ពីការផ្តល់សេវាសាធារណៈ រវាងរដ្ឋបាលកណ្តាលនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្ញើសេចក្តីប្រកាសនេះចំនួនមួយច្បាប់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជូនជ្រាបជាព័ត៌មាន និងសម្រាប់តាមដានការអនុវត្តចំណូល។

ប្រការ ៥ :

រាល់ការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយប្រកាសរួមនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបានបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ ៦ :

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវកំណត់ទីតាំងដាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។

ប្រការ ៧ :

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើរបាយការណ៍ ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដើម្បីផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

ប្រការ ៨ :

កម្រងសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ អាចកែប្រែបាន តាមការចាំបាច់តាមរយៈប្រកាសរួម។

ប្រការ ៩ :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ១០ :

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

វង សូត

ចម្លងជូនៈ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសេវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា

«ដើម្បីជូនជ្រាប»

- ដូចប្រការ ១០ «ដើម្បីមុខការ»
- ឯកសារ - កាលប្បវត្តិ

តារាងឧបសម្ព័ន្ធ

ភ្ជាប់នឹងប្រកាសរួមលេខ ១០០៩ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២

ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
1	ពិនិត្យកាយសម្បទាមុនចូលធ្វើការកម្មករនិយោជិតខ្មែរ	20,000	7ថ្ងៃ	
2	ពិនិត្យកាយសម្បទាមុនចូលធ្វើការសម្រាប់ជនបរទេស	100,000	7ថ្ងៃ	
3	ការចុះពិនិត្យកាយសម្បទាកម្មករ និយោជិតខ្មែរ មុនចូលបម្រើការងារនៅតាមសហគ្រាស-គ្រឹះស្ថាន (តាមការស្នើសុំរបស់សហគ្រាស-គ្រឹះស្ថាន)			
	- នៅរាជធានីភ្នំពេញ	24,000	1ថ្ងៃ	
	- នៅតាមបណ្តាខេត្ត	28,000	1ថ្ងៃ	
4	ការចុះពិនិត្យកាយសម្បទាកម្មករ និយោជិតបរទេស មុនចូលបម្រើការងារនៅតាមសហគ្រាស-គ្រឹះស្ថាន (តាមការស្នើសុំរបស់សហគ្រាស-គ្រឹះស្ថាន)			
	- នៅរាជធានីភ្នំពេញ	110,000	1ថ្ងៃ	
	- នៅតាមបណ្តាខេត្ត	120,000	1ថ្ងៃ	
5	ពិនិត្យសុខភាពពលករខ្មែរទៅបម្រើការងារនៅបរទេស ពិនិត្យសុខភាពសិក្ខាកាមខ្មែរទៅបរទេស (តាមការស្នើសុំ)			
5.1	ការធានាសេវាបញ្ជូនពលករ(សេវាបកប្រែឯកសារជាភាសាអង់គ្លេស)	40,000		
5.2	សេវាគ្រូពេទ្យពិនិត្យ(ត្រចៀក ច្រមុះ បំពង់ក ភ្នែក សួត បេះដូង កាយសម្បទា)	10,000		
5.3	សេវាថតវិទ្យុសាស្ត្រ	18,000		
5.4	សេវាមន្ទីរពិសោធន៍			

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
5.4.1	ផ្នែកទី1 : ពិនិត្យឈាម			
	Hematocrite	4,000	2ថ្ងៃ	
	Hematology test (Hg+Vs)	10,000	2ថ្ងៃ	
	Blood Group	4,000	2ថ្ងៃ	
	Sugar	5,000	2ថ្ងៃ	
	Total Cholesterol	8,000	2ថ្ងៃ	
	HDL-Cholesterol	7,000	2ថ្ងៃ	
	LDL-Cholesterol	9,000	2ថ្ងៃ	
	Triglyceride	6,000	2ថ្ងៃ	
	Calcium	5,000	2ថ្ងៃ	
	Uric Acid	5,000	2ថ្ងៃ	
	Albumin	5,000	2ថ្ងៃ	
	Creatinine	6,000	2ថ្ងៃ	
	Blood Urea	6,000	2ថ្ងៃ	
	Serum Iron	7,000	2ថ្ងៃ	
	HIV Antibody (Elisa)	25,000	2ថ្ងៃ	
	HBs Ag (Elisa)	18,000	2ថ្ងៃ	
	HBs Ab	20,000	2ថ្ងៃ	

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
	HCV Ab	34,000	2ថ្ងៃ	
	HAV IgM	40,000	2ថ្ងៃ	
	HAV IgG	40,000	2ថ្ងៃ	
	GOT	6,000	2ថ្ងៃ	
	GPT	6,000	2ថ្ងៃ	
	Gamma-GT	6,000	2ថ្ងៃ	
	VDRL (RPR)	10,000	2ថ្ងៃ	
	TPHA	10,000	2ថ្ងៃ	
	Malaria Parasite	6,000	2ថ្ងៃ	
	Widal	6,000	2ថ្ងៃ	
	Blood Conservation (4Months)	26,000	2ថ្ងៃ	
5.4.2	ផ្នែកទី2 : ពិនិត្យទឹកនោម			
	Albumin, Sugar (+Pregnancy Test)	8,000	2ថ្ងៃ	
	Morphine	22,000	2ថ្ងៃ	
	Methamphetamine	22,000	2ថ្ងៃ	
5.4.3	ផ្នែកទី3 : ផ្សេងៗ			
	Hearing Acuity	30,000	2ថ្ងៃ	
	ECG	20,000	2ថ្ងៃ	
	Heart Ultra-sound	60,000	2ថ្ងៃ	

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
6	បញ្ជាក់លើវិញ្ញាបនប័ត្រសុខភាពសិក្ខាកាមខ្មែរទៅបរទេសតាមការស្នើសុំ (ក្នុង 1នាក់)	20,000	1ថ្ងៃ	
7	វគ្គបណ្តុះបណ្តាលគ្រូពេទ្យសហគ្រាស និងមន្ត្រីសុវត្ថិភាពការងារ មុនចូលបម្រើការងារតាមសហគ្រាស (ក្នុង 1នាក់)	200,000		
8	បណ្តុះបណ្តាលសុខភាព និងសុវត្ថិភាពការងារសម្រាប់និយោជក និងតំណាងកម្មករ និយោជិត (ក្នុង 1នាក់)			
	- នៅរាជធានីភ្នំពេញ	50,000		
	- នៅតាមបណ្តាខេត្ត	80,000		
9	ការផ្តល់ប័ណ្ណការងារ និងសៀវភៅការងាររបស់ជនកម្ពុជា	10,000	8ថ្ងៃ	អចិន្ត្រៃយ៍
10	ការផ្តល់ប័ណ្ណការងារ និងសៀវភៅការងាររបស់ជនបរទេស	400,000	8ថ្ងៃ	1ឆ្នាំ
11	ការផ្តល់ប័ណ្ណការងារ និងសៀវភៅការងាររបស់ជនបរទេស (តំបន់អភិវឌ្ឍន៍ត្រីកោណ)	320,000	8ថ្ងៃ	1ឆ្នាំ
12	ការផ្តល់ប័ណ្ណការងារនិងសៀវភៅការងាររបស់ជនបរទេស (ជនបរទេសស្នាក់នៅអចិន្ត្រៃយ៍)	240,000	8ថ្ងៃ	
13	ការផ្តល់កូតាប្រើប្រាស់ជនបរទេសប្រចាំឆ្នាំសម្រាប់សហគ្រាស គ្រឹះស្ថាននីមួយៗ	80,000	8ថ្ងៃ	1ឆ្នាំ
14	ការចេញលិខិតទទួលស្គាល់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក			
	- សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន 08នាក់ - 100នាក់	80,000	7ថ្ងៃ	២ឆ្នាំ
	- សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន 101នាក់ - 500នាក់	150,000	7ថ្ងៃ	២ឆ្នាំ
	- សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន 501នាក់ - 800នាក់	250,000	7ថ្ងៃ	២ឆ្នាំ
	- សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន 801នាក់ឡើងទៅ	400,000	7ថ្ងៃ	២ឆ្នាំ

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
15	ការចុះបញ្ជិកាសំណុំបែបបទ ស្តីពីគ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 01នាក់ - 07នាក់ (មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ទទួលខុសត្រូវរៀបចំសំណុំបែបបទពាក់ព័ន្ធជូនអតិថិជន ដោយឥតគិតថ្លៃ)			
	- ចុះបញ្ជិកា ប្រកាសបើកសហគ្រាស	20,000	15ថ្ងៃ	
	- ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន	20,000	7ថ្ងៃ	
	- ចុះបញ្ជិកា សៀវភៅបើកប្រាក់	40,000	7ថ្ងៃ	
16	ការចុះបញ្ជិកា និងទិដ្ឋាការសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 08នាក់ - 100នាក់ (មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ផ្តល់ជូនសៀវភៅបើកប្រាក់ សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន តែមប្រើសារពើពន្ធចំនួន 3,000រៀល និងទទួលខុសត្រូវរៀបចំសំណុំបែបបទពាក់ព័ន្ធជូនអតិថិជន ដោយឥតគិតថ្លៃ)			
	- ចុះបញ្ជិកា ប្រកាសបើកសហគ្រាស	30,000	15ថ្ងៃ	
	- ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន	40,000	7ថ្ងៃ	
	- ចុះបញ្ជិកា សៀវភៅបើកប្រាក់	60,000	7ថ្ងៃ	
	- ចុះទិដ្ឋាការ បទបញ្ជាផ្ទៃក្នុង	70,000	60ថ្ងៃ	
17	ការចុះបញ្ជិកា និងទិដ្ឋាការសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 101នាក់ - 500នាក់ (នាយកដ្ឋានអធិការកិច្ចការងារ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ផ្តល់ជូនសៀវភៅបើកប្រាក់ សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន តែមប្រើសារពើពន្ធចំនួន 3,000រៀល និងទទួលខុសត្រូវរៀបចំសំណុំបែបបទពាក់ព័ន្ធជូនអតិថិជន ដោយឥតគិតថ្លៃ)			
	- ចុះបញ្ជិកា ប្រកាសបើកសហគ្រាស	100,000	15ថ្ងៃ	
	- ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន	80,000	7ថ្ងៃ	
	- ចុះបញ្ជិកា សៀវភៅបើកប្រាក់	120,000	7ថ្ងៃ	
	- ចុះទិដ្ឋាការ បទបញ្ជាផ្ទៃក្នុង	300,000	60ថ្ងៃ	

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
18	ការចុះបញ្ជិកា និងទិដ្ឋាការសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 501នាក់ឡើងទៅ (នាយកដ្ឋានអធិការកិច្ចការងារ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ផ្តល់ជូនសៀវភៅបើកប្រាក់ សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន តែមប្រើសារពើពន្ធចំនួន 3,000រៀល និងទទួលខុសត្រូវរៀបចំសំណុំបែបបទពាក់ព័ន្ធជូនអតិថិជន ដោយឥតគិតថ្លៃ)			
	- ចុះបញ្ជិកា ប្រកាសបើកសហគ្រាស	200,000	15ថ្ងៃ	
	- ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន	80,000	7ថ្ងៃ	
	- ចុះបញ្ជិកា សៀវភៅបើកប្រាក់	120,000	7ថ្ងៃ	
	- ចុះទិដ្ឋាការ បទបញ្ជាផ្ទៃក្នុង	600,000	60ថ្ងៃ	
19	លិខិតអនុញ្ញាតធ្វើការបន្ថែមម៉ោង	100,000	7ថ្ងៃ	2ខែ
20	សំណុំបែបបទហ្វឹកហ្វឺនកូនជាងមួយឈុត	3,000		
21	ការចេញប័ណ្ណទទួលស្គាល់ជំនាញវិជ្ជាជីវៈ	3,000		
22	ការចេញវិញ្ញាបនបត្រហ្វឹកហ្វឺនកូនជាង	12,000		
23	ការចុះហត្ថលេខាលើសញ្ញាបត្រសិស្ស-និស្សិតបង់ថ្លៃ	8,000		

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២០២០ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២

ប្រកាសរួម

ស្តីពី

ការផ្តល់ទ្វាន់លើកទឹកចិត្តជូន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងប្រកាសរួមលេខ ១០០៩ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

សម្រេច

ប្រការ ១ :

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

ប្រការ ២ :

ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា រវាងរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននៃការបែងចែកភារកិច្ចក្នុងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយរដ្ឋបាលកណ្តាល និងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយមន្ទីរជំនាញរាជធានី ខេត្ត។

ប្រការ ៣ :

អនុញ្ញាតឱ្យរដ្ឋបាលកណ្តាលនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានរៀងៗខ្លួនពីការផ្តល់សេវាសាធារណៈ ដូចបានកំណត់ដោយប្រកាសរួមលេខ ១០០៩ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់នេះ ត្រូវបានចាត់ទុកថា ថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទានជូនរដ្ឋបាលកណ្តាលនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រី និងពង្រឹងយន្តការប្រមូលចំណូល ដែលបានកំណត់នៅក្នុងប្រការ១ នៃប្រកាសរួមនេះ។ ប្រាក់រង្វាន់ដែលអនុញ្ញាតឱ្យកាត់ទុកជាមុននេះ រួមមានចំណែកប្រាក់រង្វាន់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ ៤ :

ការផ្ដល់ប្រាក់រង្វាន់ជូនក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបាន និងត្រូវបានបែងចែក ដូចខាងក្រោម ៖

ក. ការបែងចែកសម្រាប់រដ្ឋបាលកណ្ដាល

- បង់ចូលថវិកាជាតិ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ

ខ. ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត

- បង់ចូលថវិកាជាតិ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈរាជធានី ខេត្ត តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ

ប្រការ ៥ :

រដ្ឋបាលកណ្ដាលនៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្ដល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។ រដ្ឋបាលកណ្ដាលនៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់រដ្ឋបាលកណ្ដាលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់រដ្ឋបាលកណ្ដាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈដែរ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទានពីថវិកាជាតិ(ប្រាក់ចំណូលដែលបានកាត់ទុកជាមុន)។

ការកត់ត្រាចំណូល និងចំណាយក្នុងកិច្ចប្រតិបត្តិការថវិកាជាតិ លើការផ្ដល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីទូទាត់ប្រាក់បុរេប្រទាន ដូចខាងក្រោម ៖

ក. ផ្នែកចំណូលៈត្រូវធ្វើសលាកប័ត្រចំណូលថវិកាជាតិ នូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន ៖

- ចំពោះរដ្ឋបាលកណ្តាលនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។
- ចំពោះមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្តត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។

ខ. ផ្នែកចំណាយៈ ត្រូវធ្វើអាណត្តិបើកប្រាក់ ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

ប្រការ ៦ :

ក្រោយពីបានបំពេញនីតិវិធី ដែលមានចែងក្នុងប្រការ ៥ ខាងលើ ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តត្រូវអនុវត្ត ដូចខាងក្រោម ៖

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ប្រការ ៧ :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៨ :

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

វង សូត

ចម្លងជូនៈ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត

«ដើម្បីជូនជ្រាប»
- ដូចប្រការ ៨ «ដើម្បីមុខការ»
- ឯកសារ - កាលប្បវត្តិ

តារាងឧបសម្ព័ន្ធ

ភ្ជាប់នឹងប្រកាសរួមលេខ ១០១០ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២

ស្តីពីការផ្តល់ទ្រាន់លើកទឹកចិត្ត ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(ក. កបវ) និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(ក. សហវ)

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. កបវ	ក. សហវ
1	ពិនិត្យកាយសម្បទាមុនចូលធ្វើការកម្មករនិយោជិតខ្មែរ	10%	89%	1%
2	ពិនិត្យកាយសម្បទាមុនចូលធ្វើការសម្រាប់ជនបរទេស	10%	89%	1%
3	ការចុះពិនិត្យកាយសម្បទាកម្មករ និយោជិតខ្មែរ មុនចូលបម្រើការងារនៅតាមសហគ្រាស-គ្រឹះស្ថាន (តាមការស្នើសុំរបស់សហគ្រាស-គ្រឹះស្ថាន)			
	- នៅរាជធានីភ្នំពេញ	10%	89%	1%
	- នៅតាមបណ្តាខេត្ត	10%	89%	1%
4	ការចុះពិនិត្យកាយសម្បទាកម្មករ និយោជិតបរទេស មុនចូលបម្រើការងារនៅតាមសហគ្រាស-គ្រឹះស្ថាន (តាមការស្នើសុំរបស់សហគ្រាស-គ្រឹះស្ថាន)			
	- នៅរាជធានីភ្នំពេញ	10%	89%	1%
	- នៅតាមបណ្តាខេត្ត	10%	89%	1%
5	ពិនិត្យសុខភាពពលករខ្មែរទៅបម្រើការងារនៅបរទេស ពិនិត្យសុខភាពសិក្ខាកាមខ្មែរទៅបរទេស (តាមការស្នើសុំ)			
5.1	ការធានាសេវាបញ្ជូនពលករ(សេវាបកប្រែឯកសារជាភាសាអង់គ្លេស)	10%	89%	1%
5.2	សេវាគ្រូពេទ្យពិនិត្យ(ត្រចៀក ច្រមុះ បំពង់ក ភ្នែក សួត បេះដូង កាយសម្បទា)	10%	89%	1%
5.3	សេវាថតវិទ្យុសាស្ត្រ	10%	89%	1%
5.4	សេវាមន្ទីរពិសោធន៍			

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	គ. គបវ	គ. សហវ
5.4.1	ផ្នែកទី1 : ពិនិត្យឈាម			
	Hematocrite	10%	89%	1%
	Hematology test (Hg+Vs)	10%	89%	1%
	Blood Group	10%	89%	1%
	Sugar	10%	89%	1%
	Total Cholesterol	10%	89%	1%
	HDL-Cholesterol	10%	89%	1%
	LDL-Cholesterol	10%	89%	1%
	Triglyceride	10%	89%	1%
	Calcium	10%	89%	1%
	Uric Acid	10%	89%	1%
	Albumin	10%	89%	1%
	Creatinine	10%	89%	1%
	Blood Urea	10%	89%	1%
	Serum Iron	10%	89%	1%
	HIV Antibody (Elisa)	10%	89%	1%
	HBs Ag (Elisa)	10%	89%	[illegible]
	HBs Ab	10%	89%	[illegible]

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. កបវ	ក. សហវ
	HCV Ab	10%	89%	1%
	HAV IgM	10%	89%	1%
	HAV IgG	10%	89%	1%
	GOT	10%	89%	1%
	GPT	10%	89%	1%
	Gamma-GT	10%	89%	1%
	VDRL (RPR)	10%	89%	1%
	TPHA	10%	89%	1%
	Malaria Parasite	10%	89%	1%
	Widal	10%	89%	1%
	Blood Conservation (4Months)	10%	89%	1%
5.4.2	ផ្នែកទី២ : ពិនិត្យទឹកនោម			
	Albumin, Sugar(+Pregnancy test)	10%	89%	1%
	Morphine	10%	89%	1%
	Methamphetamine	10%	89%	1%
5.4.3	ផ្នែកទី៤ : ផ្សេងៗ			
	Hearing Acuity	10%	89%	1%
	ECG	10%	89%	1%
	Heart Ultra-sound	10%	89%	1%

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. កបវ	ក. សហវ
6	បញ្ជាក់លើវិញ្ញាបនប័ត្រសុខភាពសិក្ខាកាមខ្មែរទៅបរទេសតាមការស្នើសុំ(ក្នុង១នាក់)	10%	89%	1%
7	វគ្គបណ្តុះបណ្តាលគ្រូពេទ្យសហគ្រាស និងមន្ត្រីសុវត្ថិភាពការងារ មុនចូលបម្រើការងារតាមសហគ្រាស (គិតម្នាក់ៗ)	10%	89%	1%
8	បណ្តុះបណ្តាលសុខភាព និងសុវត្ថិភាពការងារសម្រាប់និយោជក និងតំណាងកម្មករ និយោជិត (គិតម្នាក់ៗ)			
	- នៅរាជធានីភ្នំពេញ	10%	89%	1%
	- នៅតាមបណ្តាខេត្ត	10%	89%	1%
9	ការផ្តល់ប័ណ្ណការងារ និងសៀវភៅការងាររបស់ជនកម្ពុជា	50%	49%	1%
10	ការផ្តល់ប័ណ្ណការងារ និងសៀវភៅការងាររបស់ជនបរទេស	70%	29%	1%
11	ការផ្តល់ប័ណ្ណការងារ និងសៀវភៅការងាររបស់ជនបរទេស (តំបន់អភិវឌ្ឍន៍ត្រីកោណ)	70%	29%	1%
12	ការផ្តល់ប័ណ្ណការងារនិងសៀវភៅការងាររបស់ជនបរទេស (ជនបរទេសស្នាក់នៅអចិន្ត្រៃយ៍)	70%	29%	1%
13	ការផ្តល់កូតាប្រើប្រាស់ជនបរទេសប្រចាំឆ្នាំសម្រាប់សហគ្រាស គ្រឹះស្ថាននីមួយៗ	50%	49%	1%
14	ការចេញលិខិតទទួលស្គាល់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក			
	- សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន ០៨នាក់-១០០នាក់	50%	49%	1%
	- សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន ១០១នាក់-១០០នាក់	50%	49%	1%
	- សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន ៥០១នាក់-៨០០នាក់	50%	49%	1%
	- សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន ៨០១នាក់ឡើង	50%	49%	1%

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. កបវ	ក. សហវ
15	ការចុះបញ្ជិកាសំណុំបែបបទ ស្តីពីគ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 01នាក់ - 07នាក់ (មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ទទួលខុសត្រូវរៀបចំសំណុំបែបបទពាក់ព័ន្ធជូនអតិថិជន ដោយឥតគិតថ្លៃ)			
	- ចុះបញ្ជិកា ប្រកាសបើកសហគ្រាស	50%	49%	1%
	- ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន	50%	49%	1%
	- ចុះបញ្ជិកា សៀវភៅបើកប្រាក់	50%	49%	1%
16	ការចុះបញ្ជិកា និងទិដ្ឋាការសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 08នាក់ - 100នាក់ (មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ផ្តល់ជូនសៀវភៅបើកប្រាក់ សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន តែមប្រើសារពើពន្ធចំនួន 3,000រៀល និងទទួលខុសត្រូវរៀបចំសំណុំបែបបទពាក់ព័ន្ធជូនអតិថិជន ដោយឥតគិតថ្លៃ)			
	- ចុះបញ្ជិកា ប្រកាសបើកសហគ្រាស	50%	49%	1%
	- ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន	50%	49%	1%
	- ចុះបញ្ជិកា សៀវភៅបើកប្រាក់	50%	49%	1%
	- ចុះទិដ្ឋាការ បទបញ្ជាផ្ទៃក្នុង	50%	49%	1%
17	ការចុះបញ្ជិកា និងទិដ្ឋាការសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 101នាក់ - 500នាក់ (នាយកដ្ឋានអធិការកិច្ចការងារ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ផ្តល់ជូនសៀវភៅបើកប្រាក់ សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន តែមប្រើសារពើពន្ធចំនួន 3,000រៀល និងទទួលខុសត្រូវរៀបចំសំណុំបែបបទពាក់ព័ន្ធជូនអតិថិជន ដោយឥតគិតថ្លៃ)			
	- ចុះបញ្ជិកា ប្រកាសបើកសហគ្រាស	50%	49%	1%
	- ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន	50%	49%	1%
	- ចុះបញ្ជិកា សៀវភៅបើកប្រាក់	50%	49%	1%
	- ចុះទិដ្ឋាការ បទបញ្ជាផ្ទៃក្នុង	50%	49%	1%

ល.រ	បរិយាយ	អត្រាបែងចែក		
		ថវិកាជាតិ	ក. កបវ	ក. សហវ
18	ការចុះបញ្ជិកា និងទិដ្ឋាការសំណុំបែបបទ ស្ដីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 501នាក់ឡើងទៅ (នាយកដ្ឋានអធិការកិច្ចការងារ ឬមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត ផ្ដល់ជូនសៀវភៅបើកប្រាក់ សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន តែមប្រើសារពើពន្ធចំនួន 3,000រៀល និងទទួលខុសត្រូវរៀបចំសំណុំបែបបទពាក់ព័ន្ធជូនអតិថិជន ដោយឥតគិតថ្លៃ)			
	- ចុះបញ្ជិកា ប្រកាសបើកសហគ្រាស	50%	49%	1%
	- ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន	50%	49%	1%
	- ចុះបញ្ជិកា សៀវភៅបើកប្រាក់	50%	49%	1%
	- ចុះទិដ្ឋាការ បទបញ្ជាផ្ទៃក្នុង	50%	49%	1%
19	លិខិតអនុញ្ញាតធ្វើការបន្ថែមម៉ោង	50%	49%	1%
20	សំណុំបែបបទហ្វឹកហ្វឺនកូនជាងមួយឈុត	10%	89%	1%
21	ការចេញប័ណ្ណទទួលស្គាល់ជំនាញវិជ្ជាជីវៈ	10%	89%	1%
22	ការចេញវិញ្ញាបនបត្រហ្វឹកហ្វឺនកូនជាង	10%	89%	1%
23	ការចុះហត្ថលេខាលើសញ្ញាបត្រសិស្ស-និស្សិតបង់ថ្លៃ	10%	89%	1%

បញ្ជាក់: ចំពោះចំណូលដែលប្រមូលបានពីការផ្ដល់សេវាសាធារណៈដោយមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈរាជធានី ខេត្ត [illegible] ជូនមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈរាជធានី ខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវអនុវត្តដូចអត្រាបែងចែកមានកំណត់ក្នុងតារាងឧបសម្ព័ន្ធនេះ។